**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)**

# សេចក្ដីព្រាងយុទ្ធសាស្ត្រ

# ស្ដីពី

# និរន្តរភាពនៃការធានាគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់

**ខែឧសភា ឆ្នាំ២០២៦**

# អារម្ភកថា

រាជរដ្ឋាភិបាល មានឆន្ទៈដ៏មោះមុតក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈការអនុម័ត និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់នូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ច ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍ មូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ សំដៅរួមចំណែកលុបបំបាត់ភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង។

គណនេយ្យភាពសង្គម គឺជាអភិក្រមមួយដ៏សំខាន់ក្នុងអភិបាលកិច្ចមូលដ្ឋាន ដែលផ្តោតលើការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិលនានាក្នុងដំណើរការបំពេញការងារ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាព គុណភាព តម្លាភាព និងគណនេយ្យភាពនៃការបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានទាំងនេះ។ អាស្រ័យហេតុនេះ ការងារគណនេយ្យភាពសង្គម ត្រូវបានបញ្ជ្រាបយ៉ាងពេញលេញនៅក្នុងកម្មវិធីជាតិ និងត្រូវបានអនុវត្តក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលដៃគូ ឬអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដែលទទួលខុសត្រូវក្នុងការសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ។

ក្នុងក្របខណ្ឌកម្មវិធីជាតិ ការងារគណនេយ្យភាពសង្គម ត្រូវបានរៀបចំ និងអនុវត្ត ស្របតាមផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្តនានានៃផែនការយុទ្ធសាស្ត្រនេះ ដែលដឹកនាំ និងសម្របសម្រួលដោយគណៈកម្មាធិការគ្រប់គ្រងការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ។

យុទ្ធសាស្ត្រស្តីពីនិរន្តរភាពនៃការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ត្រូវបានរៀបចំឡើង ស្របតាមផែនការអនុវត្តគណនេយ្យភាពសង្គម តាមរយៈការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នរដ្ឋបាល ថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវានានានៅថ្នាក់ឃុំ សង្កាត់ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធនានា។ យុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើង ដើម្បីកំណត់ និងណែនាំអំពីយុទ្ធសាស្ត្រសំខាន់ៗ និងសកម្មភាពជាអាទិភាព ដើម្បីអនុវត្ត និងជានានិរន្តរភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ទូទាំងប្រទេស ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ជាពិសេសនៅក្នុងឃុំ សង្កាត់ដែលពុំមានការគាំទ្រពីអង្គការដៃគូក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ។

យុទ្ធសាស្ត្រនេះ រួមបញ្ចូលនូវផ្នែកសំខាន់ៗ ដូចជាយន្តការអនុវត្តការងារគណនេយ្យភាពសង្គម ការអភិវឌ្ឍសមត្ថភាព ការកសាងផែនការ និងការវិភាជថវិកាសម្រាប់អនុវត្តការងារគននេយ្យភាពសង្គម ការជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងការបង្កើតបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ការត្រួតពិនិត្យនិងវាយតម្លៃ និងការបង្កើតភាពជាដៃគូក្នុងការអនុវត្តការងារ

គណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់។

អាស្រ័យហេតុនេះ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវានានានៅថ្នាក់ឃុំ សង្កាត់ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា ត្រូវយកចិត្តទុកដាក់ និងអនុវត្តតាមយុទ្ធសាស្ត្រនេះ ប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ....................ខែ............ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ......... ឆ្នាំ២០២៦

**រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.គ.អ.ស.**

# មាតិកា


**អារម្ភកថា** .......... i

**បញ្ជីអក្សរកាត់** .......... iv

**១. សេចក្តីផ្តើម** .......... **១**

សារតា .......... ១
សមិទ្ធផល .......... ៤
បញ្ហាប្រឈម .......... ៦

**២. សនិទានភាព** .......... **៧**

**៣. ក្របខណ្ឌលទ្ធផល** .......... **៨**

៣.១. ចក្ខុវិស័យ .......... ៨
៣.២. គោលបំណង .......... ៨
៣.៣. គោលដៅ .......... ៩
៣.៤. យុទ្ធសាស្ត្រ .......... ៩

**៤. វិសាលភាព** .......... **៩**

**៥. អំពីយុទ្ធសាស្ត្រ** .......... **១០**

**៦. យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាព** .......... **១១**

យុទ្ធសាស្ត្រទី១ ៖ ការលើកកម្ពស់ការទទួលខុសត្រូវរបស់យន្តការគណនេយ្យភាពសង្គម .......... ១១
យុទ្ធសាស្ត្រទី២ ៖ ការអភិវឌ្ឍសមត្ថភាព .......... ១៩
យុទ្ធសាស្ត្រទី៣ ៖ ការរៀបចំ ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម .......... ២៥
យុទ្ធសាស្ត្រទី៤ ៖ ការវិភាជថវិកាគាំទ្រ ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម .......... ៣១
យុទ្ធសាស្ត្រទី៥ ៖ ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តការងារគណនេយ្យភាពសង្គម .......... ៣៤
យុទ្ធសាស្ត្រទី៦ ៖ ការអនុវត្តការងារគណនេយ្យភាពសង្គម តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល .......... ៣៧
យុទ្ធសាស្ត្រទី៧ ៖ ការជ្រើសរើស និងបង្កើតបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ .......... ៤០
យុទ្ធសាស្ត្រទី៨ ៖ ការបង្កើតភាពជាដៃគូក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម .......... ៤១

**៧. ការគ្រប់គ្រង និងការអនុវត្ត** .......... **៤៤**

**៨. ការត្រួតពិនិត្យ និងការវាយតម្លៃ** .......... **៤៥**

**៩. ផែនការថវិកា** .......... **៤៥**

៩.១. ផែនការថវិកា .......... ៤៥
៩.២. ប្រភពថវិកា .......... ៤៦

**១០. សេចក្តីសន្និដ្ឋាន** .......... **៤៧**

# បញ្ជីអក្សរកាត់

| ពាក្យកាត់ | អត្ថន័យពេញ |
|---|---|
| គ.ជ.អ.ប. | គណកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| កជទី២ | កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) |
| ផអ៥ទី១ | ផែនការអនុវត្តរយៈពេលប្រាំឆ្នាំដំណាក់កាលទី១ (២០២១-២០២៥) នៃកជទី២ |
| គ.គ.អ.ស. | គណៈកម្មាធិការគ្រប់គ្រងការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ |
| ផ.ស.រ.គ. | ផែនការសកម្មភាពរួមគណនេយ្យភាពសង្គម |
| គ.គ.ម.ស. | គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព |
| គ.ក.ស.ក. | គណកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| អ.ក.ន.ក. | អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| គ.ផ.ថ. | គណៈកម្មាធិការកសាងផែនការឃុំ សង្កាត់ |
| I4Cs | ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| Post-on | ទិន្នន័យលទ្ធផលការងារ |
| CAF | អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ |
| ISAF | ផែនការអនុវត្តគណនេយ្យភាពសង្គម |

## ១. សេចក្តីផ្តើម

១.១. សាវតា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) គឺជាគណៈកម្មាធិការអន្តរក្រសួង និងមានតួនាទីសំខាន់ក្នុងការជួយរាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្រប សម្រួល រៀបចំ និងអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ លេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការជួយ គ.ជ.អ.ប. ក្នុងការគ្រប់គ្រង រៀបចំ និងអនុវត្តប្រចាំថ្ងៃនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលជាផែនទីបង្ហាញផ្លូវរយៈពេលវែងសម្រាប់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

បច្ចុប្បន្ន គ.ជ.អ.ប បាន និងកំពុងដឹកនាំ និងសម្របសម្រួលការអនុវត្តកម្មវិធីជាតិរយៈពេល១០ ឆ្នាំសម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ (កជទី២) បន្ទាប់ពីការបញ្ចប់ដោយជោគជ័យនូវការអនុវត្ត កជទី១ (២០១០-២០២០) នៅចុងឆ្នាំ ២០២០។ គោលបំណងរបស់ កជទី២ គឺលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ប្រកបដោយសមភាពយេនឌ័រ បរិយាបន្ន សមធម៌សង្គម និងយុត្តិធម៌ សំដៅរួមចំណែកលុបបំបាត់ភាពក្រីក្រ និងកែលម្អគុណភាពជីវិតរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង។ ដើម្បីសម្រេចបានគោលបំណងនេះ កជទី២ បានកំណត់សមាសភាគចំនួន៥ដែលត្រូវអនុវត្តរួមមាន (១) ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ (២) រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ (៣) ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស (៤) វិមជ្ឈការហិរញ្ញវត្ថុ ប្រព័ន្ធផែនការ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និង (៥) ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ទន្ទឹមនេះ ការអនុវត្ត កជទី២ ក៏ផ្តោតការយកចិត្តទុកដាក់លើការងារអន្តរវិស័យសំខាន់ៗចំនួន៣ គឺ (១) សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម (២) ការប្រែប្រួលអាកាសធាតុ និង (៣) អភិបាលកិច្ចបរិវត្តកម្មឌីជីថល។ ក្នុងការអនុវត្ត កជទី២ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការ និងធនធានវិការបស់ខ្លួន ដើម្បីផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយគ្មានការរើសអើងទាំងផ្នែកយេនឌ័រ សាសនា ពិការភាព ជនជាតិដើមភាគតិច ឬលក្ខណៈសង្គមផ្សេងទៀត។ រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវនឹងធ្វើការយ៉ាងសកម្ម ដើម្បីជួយស្ត្រី និងក្រុមជនងាយរងគ្រោះនានា ប្រកបដោយសមភាព និងសមធម៌ ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាប្រឈមនានាដែលជួបប្រទះក្នុងការប្រើប្រាស់សេវាសាធារណៈ និងការចូលរួមយ៉ាងពេញលេញក្នុងការអភិវឌ្ឍមូលដ្ឋាន សេដ្ឋកិច្ច និងសង្គម។

ការដាក់ចេញនូវគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបង្ហាញពីការប្តេជ្ញាចិត្ត យ៉ាងមុតមាំរបស់រាជរដ្ឋាភិបាល និងបង្កើតបានជាជំហានដ៏សំខាន់មួយឆ្ពោះទៅមុខនៅក្នុងដំណើរការកែទម្រង់អភិបាលកិច្ចមូលដ្ឋានក្នុងគោលបំណងពង្រឹងលទ្ធិប្រជាធិបតេយ្យ លើកកម្ពស់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម សំដៅចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានផ្តល់នូវមូលដ្ឋានគ្រឹះផ្នែកច្បាប់ដ៏សំខាន់សម្រាប់ដំណើរការកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងការបង្កើតក្រុមប្រឹក្សា តាមរយៈការបោះឆ្នោតនៅថ្នាក់ក្រោមជាតិនីមួយៗ ហើយបច្ចុប្បន្ន ក្រុមប្រឹក្សាទាំងនេះកំពុងបំពេញតួនាទីជាអង្គអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន។ ក្នុងន័យនេះ ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនីមួយៗត្រូវតែមានការទទួលខុសត្រូវជាចម្បង និងដោយផ្ទាល់ចំពោះប្រជាពលរដ្ឋរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ព្រមទាំងត្រូវផ្តោតជាសំខាន់លើការលើកឡើងនូវមតិយោបល់ និងតម្រូវការនានារបស់បុរស ស្ត្រី និងក្រុមងាយរងគ្រោះនានាក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីការបែងចែក ការប្រើប្រាស់ និងការគ្រប់គ្រងធនធាននានា ក៏ដូចជាការផ្តល់សេវាសាធារណៈ សេវារដ្ឋបាល និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន។

ការងារគណនេយ្យភាពសង្គម គឺជាឧបករណ៍មួយដ៏សំខាន់ក្នុងការរួមចំណែកដល់ការពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ផ្អែកលើមូលដ្ឋាននេះ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ គ.ជ.អ.ប. បានអនុម័តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ភាគីពាក់ព័ន្ធនានាក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងក្របខណ្ឌនៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ។ ផែនការយុទ្ធសាស្ត្រនេះ បង្ហាញពីចក្ខុវិស័យ គោលបំណង លទ្ធផលដែលរំពឹងទុក និងគោលការណ៍ជាគន្លឹះនៃការងារគណនេយ្យភាពសង្គម ព្រមទាំងពិពណ៌នាអំពីយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ ដែលភាគីពាក់ព័ន្ធទាំងអស់ត្រូវតែប្រកាន់ខ្ជាប់ ដើម្បីធ្វើការរួមគ្នាសម្រាប់អនុវត្តប្រកបដោយជោគជ័យ រួមមាន (១) ការលើកកម្ពស់តម្លាភាព ការទទួលបាន និងការប្រើប្រាស់ព័ត៌មាននានាអំពីស្តង់ដា ថវិកា និងការបំពេញការងារ (២) ការណែនាំអំពីការត្រួតពិនិត្យ និងរាយការណ៍ដែលសម្របសម្រួលដោយប្រជាពលរដ្ឋអំពីការបំពេញការងារ និងការផ្តល់សេវាជាមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៣) លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៤) កៀរគរការចូលរួមជាមួយតួអង្គនានា និងកសាងជំនាញ ដើម្បីសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ និងដំណើរការគណនេយ្យភាពសង្គម និង (៥) ការប្រមូល និងចងក្រងមេរៀន-បទពិសោធន៍នានាដែលទទួលបានពីអន្តរាគមន៍នានានៅមូលដ្ឋាន និងប្រែក្លាយមេរៀន-បទពិសោធន៍ទាំងនេះឱ្យទៅជាគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការអនុវត្តជាក់ស្តែងរបស់អង្គការសង្គមស៊ីវិលនានាឱ្យកាន់តែប្រសើរឡើង។

ផ្អែកលើផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម គ.ជ.អ.ប. ក៏បានរៀបចំ និងដាក់

ឱ្យអនុវត្តជាបន្តបន្ទាប់នូវផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី១ (២០១៦-២០១៨) និងផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០១៩-២០២៥)។ ផែនការអនុវត្តគណនេយ្យភាពសង្គម គឺជាមូលដ្ឋានសម្រាប់ការរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមរបស់ភាគីពាក់ព័ន្ធនានា ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។

ផែនការគណនេយ្យភាពសង្គមដំណាក់កាលទី១ ផ្តោតលើសមាសធាតុអនុវត្តចំនួន៤ គឺ (១) តម្លាភាព ការទទួលបានព័ត៌មាន និងថវិកា (២) ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ (៣) ការសម្របសម្រួល និងការអភិវឌ្ឍសមត្ថភាព និង (៤) ការសិក្សារៀនសូត្រ និងការត្រួតពិនិត្យ។ ផ្អែកលើភាពជោគជ័យ និងមេរៀន បទពិសោធន៍នៃការអនុវត្តដំណាក់កាលទី១ ក្របខ័ណ្ឌគណនេយ្យភាពសង្គមដំណាក់កាលទី២ ត្រូវបានរៀបចំដោយផ្តោតលើសមាសភាគចំនួន ៥ គឺ (១) តម្លាភាព ការទទួលបានព័ត៌មាន និងថវិកា (២) ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ (៣) ការអនុវត្តផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម (៤) ការបណ្តុះបណ្តាល ការអភិវឌ្ឍសមត្ថភាព និងការប្រាស្រ័យទាក់ទង និង (៥) ការគ្រប់គ្រងកម្មវិធី ការត្រួតពិនិត្យ និងការវាយតម្លៃ។ ក្នុងដំណាក់កាលទី ២ មានក្រសួងពាក់ព័ន្ធចូលរួម និងទទួលខុសត្រូវកាន់តែច្រើនឡើងនៅក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ស្របតាមតួនាទី និងភារកិច្ចរបស់ខ្លួន។ លេខាធិការដ្ឋាន គ.ជ.អ.ប. នៅតែដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលសកម្មភាពគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ និងការប្រាស្រ័យទាក់ទងជាមួយអ្នកសម្របសម្រួលផ្នែកតម្រូវការ ដើម្បីត្រួតពិនិត្យការផលិតព័ត៌មានប្រចាំឆ្នាំសម្រាប់ប្រជាពលរដ្ឋ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យការអនុវត្ត ផ.ស.រ.គ. ការដាក់ចេញនូវសេចក្តីណែនាំស្តីពីការងារគណនេយ្យភាពសង្គម និងការរៀបចំវគ្គបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព និងការគាំទ្របច្ចេកទេសអំពីការងារគណនេយ្យភាពសង្គមដល់រដ្ឋបាល ថ្នាក់ក្រោមជាតិ ព្រមទាំងការគាំទ្រក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការបញ្ចូលការងារគណនេយ្យភាពសង្គមទៅក្នុងគោលនយោបាយ រចនាសម្ព័ន្ធ ប្រព័ន្ធ និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

គម្រោងគាំទ្រការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម

គម្រោងសមាហរណកម្មនៃគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០១៩ តាមរយៈមូលនិធិនៃពហុដៃគូអភិវឌ្ឍន៍នៃការផ្តល់សេវា និងគណនេយ្យភាពសង្គម (SASD-MDTF) ដែលសម្របសម្រួលដោយធនាគារពិភពលោក និងផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលស្វីស និងអាល្លឺម៉ង់ ដើម្បីគាំទ្រដល់ការងារគណនេយ្យភាពសង្គម "ផ្នែកផ្គត់ផ្គង់" ដែលអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផ្តល់ព័ត៌មាននានាដែលប្រជាពលរដ្ឋត្រូវការ ដើម្បីធ្វើឱ្យអង្គភាពផ្តល់សេវាសាធារណៈមានគណនេយ្យភាព និងកសាងឆន្ទៈ និងសមត្ថភាពរបស់មន្ត្រីរាជការក្នុងការឆ្លើយតបចំពោះមតិយោបល់ និងតម្រូវការនានារបស់ប្រជាពលរដ្ឋ។ គម្រោងនេះមានគោលបំណងបង្កើនប្រសិទ្ធភាពនៃការអនុវត្តរបស់អង្គភាពផ្តល់សេវាសាធារណៈតាមរយៈការអភិវឌ្ឍ និងការធ្វើស្ថាប័ន

ភាវូបនីយកម្មក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ គម្រោងក៏ត្រូវបានបំពេញបន្ថែមដោយគម្រោងមួយទៀត ដែលត្រូវបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល គឺអង្គការទស្សនពិភពលោក ដើម្បីពង្រឹងគណនេយ្យភាពសង្គម "ផ្នែកតម្រូវការ" ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋមានចំណេះដឹងកាន់តែច្រើនអំពីសេវាសាធារណៈ ស្តង់ដាសេវា និងការបំពេញការងារ និងសិទ្ធិរបស់ប្រជាពលរដ្ឋ និងចូលរួមកាន់តែសកម្មក្នុងការទាមទារ និងរួមចំណែកក្នុងការកែលម្អគុណភាព និងការអនុវត្តរបស់អង្គភាពផ្តល់សេវា។ ចាប់តាំងពីឆ្នាំ២០២៤ គម្រោងទាំងនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយមូលនិធិនៃភាពជាដៃគូរវាងអូស្ត្រាលី-ធនាគារពិភពលោកសម្រាប់ការលើកកម្ពស់បរិយាប័ន្ន និរន្តរភាព និងសមភាពនៅកម្ពុជា (PROMISE Trust Fund)។ គម្រោងទាំងពីរត្រូវបានបញ្ចប់នៅចុងឆ្នាំ២០២៦។

ជារួម គម្រោងទាំង២មានសមាសភាគចំនួន ៥ រួមបញ្ចូលសមាសភាគសំខាន់ៗចំនួន៣ ដែលពាក់ព័ន្ធនឹងសកម្មភាពនៃវដ្តគណនេយ្យភាពសង្គមប្រចាំឆ្នាំ ៖ (១) តម្លាភាព និងការទទួលបានព័ត៌មាន (២) ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ; (៣) ការអនុវត្តផែនការសកម្មភាពរួមនៃគណនេយ្យភាពសង្គម (៤) ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព និង (៥) ការសម្របសម្រួល និងភាពជាដៃគូរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្តោតលើការគាំទ្រដល់ការកសាងសមត្ថភាពដែលត្រូវការ ដើម្បីអនុវត្តសកម្មភាពដែលបានគ្រោងទុក និងធានានិរន្តរភាពការងារនេះបន្ទាប់ពីគម្រោងត្រូវបានបញ្ចប់។

## ១.២. សមិទ្ធផលនៃការអនុវត្តការងារគណនេយ្យភាពសង្គម

រហូតមកដល់ពេលបច្ចុប្បន្ន ផែនការគណនេយ្យភាពសង្គមត្រូវបាន និងកំពុងអនុវត្តដោយជោគជ័យនៅក្នុងរាជធានី ខេត្តទាំង២៥ ក្រុង ស្រុក ខណ្ឌចំនួន១៩០ (ស្មើនឹង៩០%) នៃក្រុង ស្រុក ខណ្ឌសរុបចំនួន២១០ និងឃុំ សង្កាត់ចំនួន១.៥៥០ (ស្មើនឹង៩៤%) នៃឃុំ សង្កាត់សរុបចំនួន១.៦៥២ ទូទាំងប្រទេស។ នៅថ្នាក់ឃុំ សង្កាត់ ការងារគណនេយ្យភាពសង្គមផ្តោតលើការលើកកម្ពស់ការផ្តល់សេវាចំនួន ៣ គឺសេវារដ្ឋបាលឃុំ សង្កាត់ សេវាមណ្ឌលសុខភាពដែលចូលរួមអនុវត្តដោយមណ្ឌលសុខភាពចំនួន ១.២៥៦ ស្មើនឹង៩៦%នៃមណ្ឌលសុខភាពទូទាំងប្រទេស និងសេវាសាលាបឋមសិក្សាដែលចូលរួមអនុវត្តដោយសាលាសិក្សាចំនួន ៩.៦២២ ស្មើនឹង៩៤%នៃសាលាបឋមសិក្សាទូទាំងប្រទេស។

តាមរយៈការអនុវត្តផែនការគណនេយ្យភាពសង្គម សមិទ្ធផលដ៏សំខាន់បំផុតដែលទទួលបាន គឺការងារនេះបានលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិលនានាក្នុងដំណើរការបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព គុណភាព និងគណនេយ្យភាព។ ទន្ទឹមនេះ ការងារគណនេយ្យភាពសង្គមក៏បានបង្កើនភាពជាដៃគូក្នុងការបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរវាងរដ្ឋបាលឃុំ សង្កាត់ (អ្នកអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់) អង្គការសង្គមស៊ីវិល (អ្នកសម្របសម្រួលការងារ និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ)។

ផ្អែកលើលទ្ធផលនៃការវាយតម្លៃលើផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី១ និងទី២ សមិទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន ៖

- តាមរយៈការផ្សព្វផ្សាយ I4Cs ប្រជាពលរដ្ឋចំនួន ៨៥% បានយល់ដឹងអំពីការងារគណនេយ្យភាពសង្គម សេវា ស្តង់ដា តួនាទីនិងភារកិច្ចរបស់អង្គភាពផ្តល់សេវា និងសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវានៅថ្នាក់ឃុំ សង្កាត់
- ប្រជាពលរដ្ឋចំនួន ៩៣% ពេញចិត្តនឹងការបំពេញការងារ និងការផ្តល់សេវារបស់អង្គភាពផ្តល់សេវា ព្រមទាំងទទួលស្គាល់ថា បរិមាណ និងគុណភាពនៃសេវាមានការផ្លាស់ប្តូរជាវិជ្ជមាន
- ៩៤% នៃប្រជាពលរដ្ឋ អង្គភាពផ្តល់សេវា និងរដ្ឋបាលថ្នាក់ក្រោមជាតិយល់ថា ការកែលម្អសេវាបានរួមចំណែកដោយផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ចំនួនជាង ៤.៥០០ នាក់ ជាប្រជាពលរដ្ឋត្រូវបានជ្រើសរើស និងបំពេញការងារយ៉ាងសកម្ម ប្រកបដោយប្រសិទ្ធភាព និងអព្យាក្រឹតភាពក្នុងការសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ ដោយក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលឃុំ សង្កាត់។ ទន្ទឹមនេះ បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ត្រូវបានបង្កើតនៅថ្នាក់រាជធានី ខេត្តចំនួន២១ និងថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន១២៨ ដើម្បីសម្របសម្រួល អភិវឌ្ឍសមត្ថភាព និងគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- ឃុំ សង្កាត់គោលដៅបានវិភាជថវិការបស់ខ្លួនចំនួនជាមធ្យម ២ លានរៀល ដើម្បីគាំទ្រកិច្ចប្រតិបត្តិការ និងសកម្មភាពសេវាសង្គម រួមបញ្ចូលការឧបត្ថម្ភ និងសកម្មភាពរបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- ៣៦% នៃសកម្មភាពរបស់ ផ.ស.រ.គ. (សកម្មភាពសរុបចំនួន ១១.១២៧) ត្រូវបានអនុវត្ត និងគាំទ្រដោយមូលនិធិឃុំ សង្កាត់
- រដ្ឋបាលឃុំ សង្កាត់បានវិភាជថវិកាចំនួន ៤ លានរៀល ស្មើនឹង ១.០០០ ដុល្លារ ដើម្បីគាំទ្រការងារគណេនេយ្យភាពសង្គម រួមបញ្ចូលចំណាយប្រតិបត្តិការ និងការគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- ចំណាយសម្រាប់ការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ត្រូវបានកំណត់ក្នុងសារាចរអន្តរក្រសួងលេខ០០៧ ឆ្នាំ២០២៥ រវាងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់
- សៀវភៅណែនាំស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។

១.៣. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផលដែលទទួលបានខាងលើ ការអនុវត្តការងារគណនេយ្យភាពសង្គម ក៏បានជួប

ប្រទះនូវបញ្ហាប្រឈមសំខាន់ៗមួយចំនួនដូចមានសង្ខេបខាងក្រោម ៖

- ព័ត៌មានអំពីការងារគណនេយ្យភាពសង្គម ពុំទាន់បានអនុវត្ត និងផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋទូទាំងប្រទេស ជាហេតុនាំឱ្យការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការដំណើរការបំពេញការងារ និងការផ្តល់សេវារបស់អង្គភាពផ្តល់សេវានៅមានកម្រិត
- ការអនុវត្តសកម្មភាពមួយចំនួននៃគណនេយ្យភាពសង្គម ដូចជាការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ការរៀបចំកិច្ចប្រជុំវាយតម្លៃ និងដាក់ពិន្ទុដោយប្រជាពលរដ្ឋលើលទ្ធផលនៃការបំពេញការងារ ការរៀបចំកិច្ចប្រជុំរួមដើម្បីរៀបចំ ផ.ស.រ.គ.... ត្រូវចំណាយពេលវេលា និងថវិកាច្រើន ព្រមទាំងត្រូវមានសមត្ថភាពសមស្រប
- ការឧបត្ថម្ភ និងការលើកទឹកចិត្តអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅមានកម្រិតទាប ដែលមិនអាចទាក់ទាញប្រជាពលរដ្ឋចូលរួម និងបម្រើការងារនេះបានផុសផុល។
- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មួយចំនួន (ចំនួនប្រមាណ១៣%) ជាមន្ត្រីភូមិ និងជំនួយការរដ្ឋបាលឃុំ សង្កាត់ ដែលប៉ះពាល់ដល់អព្យាក្រឹតភាព និងប្រសិទ្ធភាពក្នុងការសម្របសម្រួលជាមួយប្រជាពលរដ្ឋ ដើម្បីកំណត់អំពីបញ្ហា និងតម្រូវការនៃបំពេញការងារ និងការផ្តល់សេវារបស់អង្គភាពផ្តល់សេវា
- ពុំទាន់មានសេចក្តីណែនាំជាផ្លូវការពីថ្នាក់ជាតិ អំពីការបង្កើតបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលប៉ះពាល់ដល់ការប្រាស្រ័យទាក់ទង សម្របសម្រួល ការគាំទ្រ និងការអភិវឌ្ឍសមត្ថភាពដល់អ្នកសម្របសម្រួលគណនេយ្យភាពសង្គមថ្នាក់ឃុំ សង្កាត់
- ពុំទាន់មានការចូលរួមផុសផុលអំពីអង្គការសង្គមស៊ីវិល និងអង្គការសហគមន៍មូលដ្ឋាននានាក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម
- ថវិកាសម្រាប់គាំទ្រប្រតិបត្តិការ និងសកម្មភាព និងគម្រោងនៃការងារគណនេយ្យភាពសង្គមនៅមានកម្រិតទាប និងមិនសមស្របតាមតម្រូវការនៃការងារគណនេយ្យភាពសង្គមនៅតាមថ្នាក់រដ្ឋបាលនីមួយៗ។ ជាមួយគ្នានេះដែរ មិនទាន់មានការណែនាំច្បាស់លាស់ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិក្នុងកំណត់ និងវិភាជថវិកាសម្រាប់គាំទ្រការងារគណនេយ្យភាពសង្គម តាមថ្នាក់រដ្ឋបាលនីមួយៗ ពោលគឺការវិភាជថវិកា ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម ផ្អែកតាមការយកចិត្តទុក និងផ្តល់អាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។
- ការអនុវត្តការងារគណនេយ្យភាពសង្គម នៅមានលក្ខណៈជាគម្រោង ដែលទទួលការគាំទ្រពីដៃគូអភិវឌ្ឍផ្សេងៗតាមរយៈធនាគារពិភាពលោក និងអង្គការទស្សនពិភពលោក។

**២. សន្និដ្ឋានភាព**

ដូចបានរៀបរាប់ខាងលើ ចាប់តាំងពីឆ្នាំ២០១៣ មក ការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការចូលរួមរបស់ពលរដ្ឋ និងការកែលម្អប្រសិទ្ធភាព

គុណភាព និងគណនេយ្យភាពនៃការផ្តល់សេវាមូលដ្ឋាន ដោយផ្តោតលើសេវាសំខាន់ៗចំនួន ៣ គឺសេវារដ្ឋបាលឃុំ សង្កាត់ សេវាមណ្ឌលសុខភាព និងសេវាសាលាបឋមសិក្សា។ ការងារនេះបានបង្កើតវេទិកា និងឱកាសសម្រាប់ប្រជាពលរដ្ឋក្នុងការបញ្ចេញមតិយោបល់ ផ្តល់យោបល់ត្រឡប់ និងកិច្ចសហការរវាងប្រជាពលរដ្ឋជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពផ្តល់សេវានានា ដើម្បីដោះស្រាយបញ្ហា និងតម្រូវការនានានៃបំពេញការងារ និងការផ្តល់សេវា។ វិធីសាស្ត្រនៃការចូលរួមរបស់ប្រជាពលរដ្ឋនេះ មិនត្រឹមតែបានលើកកម្ពស់តម្លាភាព និងការឆ្លើយតបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើអាជ្ញាធរមូលដ្ឋានផងដែរ។

ផ្អែកតាម ផអ៥ទី១ ការងារគណនេយ្យភាពសង្គម ត្រូវអនុវត្តនៅគ្រប់ឃុំ សង្កាត់ទាំងអស់ និង ៥០% នៃក្រុង ស្រុក ខណ្ឌទាំងប្រទេសនៅឆ្នាំ២០២៥។ ប៉ុន្តែ គិតត្រឹមឆ្នាំ២០២៥ ការងារគណនេយ្យភាពសង្គមបានអនុវត្តក្នុងឃុំ សង្កាត់ចំនួន១.៥៥០ ឃុំ សង្កាត់ ស្មើនឹង៨៤%នៃឃុំ សង្កាត់ទូទាំងប្រទេស ក្នុងនោះមានឃុំ សង្កាត់ចំនួន១.០៧១ ស្មើនឹង ៧០% ដែលបានអនុវត្តការងារគណនេយ្យភាពសង្គមទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ មានក្រុង ស្រុក ខណ្ឌចំនួន៥៤ ស្មើនឹង២៦% នៃក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដែលបានអនុវត្តការងារគណនេយ្យភាពសង្គម ក្នុងនោះមានក្រុង ស្រុក ខណ្ឌចំនួន៣៧ ស្មើនឹង៧០% ដែលបានអនុវត្តការងារគណនេយ្យភាពសង្គមទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។

ដើម្បីធានាការសម្រេចបានផែនការគ្រប់ដណ្តប់របស់ ផអ៥ទី១ និងធានានិរន្តរភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ជាពិសេសនៅពេលការគាំទ្រពីដៃគូសម្រាប់ការអនុវត្តផ្នែកតម្រូវការត្រូវបានបញ្ចប់ ចាំបាច់ត្រូវធ្វើស្ថាប័នភាវូបនីយកម្មនៃការងារនេះទៅក្នុងរចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធរបស់រដ្ឋបាលឃុំ សង្កាត់។

យុទ្ធសាស្ត្រស្តីពីការធ្វើស្ថាប័នភាវូបនីយកម្មនៃការងារគណនេយ្យភាពសង្គម មានសារសំខាន់ក្នុងការធានានិរន្តរភាព និងផលប៉ះពាល់រយៈពេលវែងនៃការងារនេះនាពេលអនាគត ពោលគឺបើពុំមានការធ្វើសមាហរណកម្មជាផ្លូវការទៅក្នុងប្រព័ន្ធរបស់រដ្ឋទេ ការងារគណនេយ្យភាពសង្គមនឹងប្រឈមហានិភ័យនៃការអនុវត្តក្នុងលក្ខណៈជាគម្រោងដាច់ដោយឡែក និងបន្តពឹងផ្អែកលើការគាំទ្រពីខាងក្រៅ។ ការធ្វើស្ថាប័នភាវូនីយកម្មនឹងបញ្ចូលការអនុវត្តការងារគណនេយ្យភាពសង្គមទៅក្នុងការបំពេញការងារប្រចាំថ្ងៃ និងការផ្តល់សេវារបស់រដ្ឋបាលរដ្ឋបាលឃុំ សង្កាត់ ដែលនឹងធ្វើឱ្យការចូលរួមរបស់ប្រជាពលរដ្ឋក្លាយជាការងារអចិន្ត្រៃយ៍ និងជាប្រចាំនៃអភិបាលកិច្ចមូលដ្ឋាន។ ជាមួយគ្នានេះដែរ ការងារនេះក៏នឹងធ្វើឱ្យមានលក្ខណៈជាស្តង់ដានៃយន្តការ និងឧបករណ៍នានា ដូចជាការវាយតម្លៃ និងការដាក់ពិន្ទុរបស់ប្រជាពលរដ្ឋលើការលទ្ធផលនៃការផ្តល់សេវា ការរៀបចំកិច្ចប្រជុំរួម និងការផ្សព្វផ្សាយព័ត៌មានសាធារណៈ ដោយធានាបាននូវភាពស៊ីសង្វាក់គ្នារវាងឃុំ សង្កាត់នានាទូទាំងប្រទេសក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម។

លើសពីនេះ ការធ្វើស្ថាប័នភាវូបនីយកម្មនឹងពង្រឹងសមត្ថភាពរបស់មន្ត្រីមូលដ្ឋាន និងអង្គភាពផ្តល់

សេវាក្នុងការឆ្លើយតប ប្រកបដោយប្រសិទ្ធភាពចំពោះមតិយោបល់ត្រឡប់របស់ប្រជាពលរដ្ឋ ហើយក្នុងពេលជាមួយគ្នានេះ ក៏រក្សាបាននូវការពង្រឹងសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើភាពជាម្ចាស់ក្នុងការត្រួតពិនិត្យ និងកែលម្អសេវានានា។ តាមរយៈការតម្រឹមនៃការងារគណនេយ្យភាពសង្គមជាមួយនឹងគោលនយោបាយជាតិ និងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ យុទ្ធសាស្ត្រនិរន្តរភាពនេះនឹងធានាថាការងារគណនេយ្យភាពសង្គម មិនត្រូវបានគេមើលឃើញថាជាកម្មវិធីរបស់អង្គការ និងជាការតម្រូវពីខាងក្រៅ ប៉ុន្តែការងារនេះជាគោលការណ៍ស្នូលនៃអភិបាលកិច្ចរបស់រដ្ឋាភិបាល។

វិធីសាស្ត្រនេះក៏នឹងលើកទឹកចិត្តដល់ការបែងចែកធនធានពីថវិការដ្ឋាភិបាល ដោយកាត់បន្ថយការពឹងផ្អែកលើមូលនិធិរបស់ដៃគូអភិវឌ្ឍន៍ សំដៅពង្រឹងនិរន្តរភាពនៃការងារគណនេយ្យភាពសង្គម។ លើសពីនេះទៀត ការធ្វើស្ថាប័នភាវូបនីយកម្មនៃការងារគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលនៃអង្គភាពផ្តល់សេវានានា និងការចាប់ផ្តើមទទួលខុសត្រូវទាំងស្រុងលើការងារនេះពីឆ្នាំ២០៣០ នឹងពង្រឹងបន្ថែមលើសមិទ្ធផលនានាដែលសម្រេចបានតាំងពីឆ្នាំ២០១៣ និងធានាបាននូវការចូលរួមរបស់ប្រជាពលរដ្ឋដែលជាមូលដ្ឋានគ្រឹះនៃអភិបាលកិច្ចមូលដ្ឋាន សំដៅរួមចំណែកក្នុងការលើកកម្ពស់សមិទ្ធផលនានានៃការផ្តល់សេវាឱ្យកាន់តែប្រសើរឡើង និងផ្តល់ផលប្រយោជន៍ដោយផ្ទាល់ជូនប្រជាពលរដ្ឋ។

## ៣. ក្របខណ្ឌលទ្ធផល

### ៣.១. ចក្ខុវិស័យ

យុទ្ធសាស្ត្រស្តីពីនិរន្តរភាពនៃការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ គឺ "**ការងារគណនេយ្យភាពសង្គម ត្រូវបានធ្វើស្ថាប័នភាវូបនីយកម្មក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធនៃអង្គភាពផ្តល់សេវានៅថ្នាក់ឃុំ សង្កាត់ និងត្រូវបានអនុវត្ត តាមរយៈដំណើរការនៃការចូលរួមរបស់ប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព តម្លាភាព សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។**"

### ៣.២. គោលបំណង

យុទ្ធសាស្ត្រស្តីពីនិរន្តរភាពគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ត្រូវបានរៀបចំឡើងក្នុងគោលបំណង "**លើកកម្ពស់ភាពជាភាពម្ចាស់ និងការទទួលខុសត្រូវរបស់អង្គភាពផ្តល់សេវានៅថ្នាក់សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ក្នុងភាពជាដៃគូជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលនានា និងស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។**"

### ៣.៣. គោលដៅ

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ គោលដៅរបស់យុទ្ធសាស្ត្រនេះ "**អង្គភាពផ្តល់សេវានៅថ្នាក់ឃុំ សង្កាត់មានសិទ្ធិអំណាច មុខងារ សមត្ថភាព និងធនធានសមស្របសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម។**"

### ៣.៤. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបានគោលដៅខាងលើ យុទ្ធសាស្ត្រស្តីពីនិរន្តរភាពនៃការងារគណនេយ្យភាពសង្គម នៅថ្នាក់ឃុំ សង្កាត់បានកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗចំនួន ៨ ដើម្បីអនុវត្ត ដូចមានរៀបរាប់ខាងក្រោម ៖

- យុទ្ធសាស្ត្រទី១ ៖ ការលើកកម្ពស់ការទទួលខុសត្រូវរបស់យន្តការគណនេយ្យភាពសង្គម
- យុទ្ធសាស្ត្រទី២ ៖ ការអភិវឌ្ឍសមត្ថភាពអំពីការងារគណនេយ្យភាពសង្គម
- យុទ្ធសាស្ត្រទី៣ ៖ ការរៀបចំ ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម
- យុទ្ធសាស្ត្រទី៤ ៖ ការវិភាជថវិកាគាំទ្រ ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម
- យុទ្ធសាស្ត្រទី៥ ៖ ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តការងារគណនេយ្យភាពសង្គម
- យុទ្ធសាស្ត្រទី៦ ៖ ការអនុវត្តការងារគណនេយ្យភាពសង្គម តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល
- យុទ្ធសាស្ត្រទី៧ ៖ ការជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងបង្កើតបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- យុទ្ធសាស្ត្រទី៨ ៖ ការលើកកម្ពស់ភាពជាដៃគូក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម

សកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រទាំងនេះ មានរៀបរាប់នៅក្នុងផ្នែកទី ៦ ខាងក្រោម។

## ៤. វិសាលភាព

យុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់ការអនុវត្តការងារគណនេយ្យភាពសង្គម នៅថ្នាក់ឃុំ សង្កាត់ទូទាំងប្រទេស ជាពិសេសនៅក្នុងឃុំ សង្កាត់ដែលពុំមានការគាំទ្រពីអង្គការសង្គមស៊ីវិលក្នុងការសម្របសម្រួល និងអនុវត្តការងារគណនេយ្យសង្គមផ្នែកតម្រូវការ ពោលគឺរដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។

ថ្នាក់ឃុំ សង្កាត់ការអនុវត្តការងារគណនេយ្យភាពសង្គមផ្តោតលើការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការបំពេញការងារ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់។ សេវាសាធារណៈដែលគ្របដណ្តប់ដោយការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់មានចំនួន ៣ គឺ សេវារដ្ឋបាលឃុំ សង្កាត់ សេវាសុខាភិបាលនៅមណ្ឌលសុខភាព/ ប៉ុស្តិ៍សុខភាព និងសេវាអប់រំនៅសាលាបឋមសិក្សា។

## ៥. អំពីយុទ្ធសាស្ត្រ

ឯកសារយុទ្ធសាស្ត្រស្តីពីនិរន្តរភាពនៃការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ៖

- ផ្តល់ការណែនាំ និងប្រើប្រាស់ជាផែនទីបង្ហាញផ្លូវក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ រួមបញ្ចូលចក្ខុវិស័យ គោលបំណង គោលដៅ និងវិសាលភាពនៃ

យុទ្ធសាស្ត្រស្ដីពីនិរន្តរភាពគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់
- ណែនាំ និងរៀបរាប់អំពីយុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពដែលត្រូវអនុវត្ត ដើម្បីជានានិរន្តរភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់
- រៀបរាប់អំពីការរៀបចំស្ថាប័នសម្រាប់ការគ្រប់គ្រង និងការអនុវត្តយុទ្ធសាស្ត្រនេះ
- រៀបរាប់អំពីវិធីសាស្ត្រដែលត្រូវអនុវត្តក្នុងការត្រួតពិនិត្យ ការវាយតម្លៃ និងការចែករំលែកមេរៀនបទ ពិសោធន៍ល្អៗក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម។

ឯកសារយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំ និងបែងចែកជា ១០ ផ្នែករួមមាន ៖

ផ្នែកទី១ ជាសេចក្ដីផ្ដើមដែលសង្ខេបអំពីសាវតា សមិទ្ធផល និងបញ្ហាប្រឈមនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ឃុំសង្កាត់។

ផ្នែកទី២ ជាសនិទានភាពដែលរៀបរាប់អំពីមូលហេតុ និងភាពចាំបាច់ក្នុងការរៀបចំ និងដាក់ចេញនូវយុទ្ធសាស្ត្រស្ដីពីនិរន្តរភាពនៃការងារគណនេយ្យភាពសង្គមនោថ្នាក់ឃុំ សង្កាត់។

ផ្នែកទី៣ ជាក្របខណ្ឌយុទ្ធសាស្ត្រនៃនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ រួមមានចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រ។

ផ្នែកទី៤ រៀបរាប់អំពីវិសាលភាពជណ្ដប់នៃយុទ្ធសាស្ត្រស្ដីពីនិរន្តរភាពការងារគណនេយ្យភាពសង្គមដែលត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់។

ផ្នែកទី៥ រៀបរាប់អំពីគោលបំណងនៃឯកសារយុទ្ធសាស្ត្រ និងសេចក្ដីសង្ខេបតាមផ្នែកនីមួយៗ។

ផ្នែកទី៦ ជាផ្នែកមួយដ៏មានសារសំខាន់ និងរៀបរាប់ដោយលម្អិតអំពីសកម្មភាពជាអាទិភាព និងកិច្ចការសំខាន់ៗដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រនីមួយៗ។

ផ្នែកទី៧ រៀបរាប់អំពីស្ថាប័នទទួលខុសត្រូវក្នុងការដឹកនាំ និងសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រស្ដីពីនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់។

ផ្នែកទី៨ បរិយាយអំពីយន្តការ និងវិធីសាស្ត្រសំខាន់ៗសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រ។

ផ្នែកទី៩ ជាការប៉ាន់ស្មានអំពីថវិកាដែលត្រូវការ សម្រាប់អនុវត្តយុទ្ធសាស្ត្រ និងប្រភពធនធាន។

ផ្នែកទី១០ ជាសេក្ដីសន្និដ្ឋានដែលគូសបញ្ជាក់អំពីសារសំខាន់នៃយុទ្ធសាស្ត្រស្ដីពីនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ការលើកទឹកចិត្ត និងការណែនាំដល់ស្ថានប័នអនុវត្ត និងភាគីពាក់ព័ន្ធនានាឱ្យយកចិត្តទុកដាក់ក្នុងការគាំទ្រ និងអនុវត្តយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព។

## ៦. យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាព

យុទ្ធសាស្ត្រនេះផ្តោតលើការធ្វើសមាហរណកម្ម និងពង្រឹងការអនុវត្តការងារគណនេយ្យភាពសង្គម ដោយយន្តការនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវក្នុងការដឹកនាំ សម្របសម្រួល សហការ ត្រួតពិនិត្យ តាមដាន គាំទ្រ និងចូលរួមក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ សំដៅបង្កើនប្រសិទ្ធភាព និងគណនេយ្យភាពក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមដោយយន្តការទាំងនេះ។

យន្តការសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមរួមមាន ៖

- គ.គ.អ.ស.
- ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- សាលាជាតិរដ្ឋបាលមូលដ្ឋាន
- ក្រុមការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ
- រដ្ឋបាលឃុំ សង្កាត់
- មណ្ឌលសុខភាព
- សាលាបឋមសិក្សា
- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងបណ្តាញ
- ប្រជាពលរដ្ឋ
- អង្គការសង្គមស៊ីវិលនានា

ដើម្បីសម្រេចបានយុទ្ធសាស្ត្រនេះ សកម្មភាពជាអាទិភាពដែលត្រូវយកចិត្តទុកដាក់ដោយយន្តការនីមួយៗមានរៀបរាប់ដូចខាងក្រោម ៖

*សកម្មភាពជាអាទិភាព ១.១. ៖ គ.គ.អ.ស.*

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងធានាថា គ.គ.អ.ស. នឹងដំណើរការជាធម្មតាបន្ទាប់ពីគម្រោងគាំទ្រផែនការអនុវត្តគណនេយ្យភាពសង្គម ត្រូវបានបញ្ចប់នៅចុងឆ្នាំ២០២៦
- រៀបចំ និងបញ្ចូលរបៀបវារៈនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ នៅរៀងរាល់ក្នុងកិច្ចប្រជុំរបស់ គ.គ.អ.ស.
- យកចិត្តទុកដាក់រៀបចំ និងដាក់ចេញគោលនយោបាយ លិខិតបទដ្ឋាន ឯកសារបច្ចេកទេស និងផែនការនានាដែលពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់
- ពង្រឹងការចុះត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់

- ពង្រឹងការសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ននានាក្នុងការឆ្លើយតប និងដោះស្រាយបញ្ហា និងតម្រូវការនានាដែលបានលើកឡើងដោយអង្គភាពផ្តល់សេវានៅថ្នាក់ឃុំ សង្កាត់ និងភាគីពាក់ព័ន្ធនានា
- លើកកម្ពស់កិច្ចសហការ និងការកៀរគរធនធានជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីគាំទ្រការងារអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់
- រៀបចំ និងបញ្ចូលរបាយការណ៍ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ជាប្រចាំ ដើម្បីដាក់ជូន គ.ជ.អ.ប.។

សកម្មភាពជាអាទិភាព ១.២. ៖ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប.

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ដឹកនាំ សម្របសម្រួល និងគាំទ្រក្នុងការរៀបចំ និងការអនុវត្តផែនការ យុទ្ធសាស្ត្រ ផែនការអនុវត្ត និងគម្រោងកម្មវិធីនានាស្តីពីការងារគណនេយ្យភាពសង្គម
- អភិវឌ្ឍសមត្ថភាព ត្រួតពិនិត្យ និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម
- រៀបចំ និងអនុវត្ត ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ រួមបញ្ចូលការអភិវឌ្ឍសមត្ថភាព ការត្រួតពិនិត្យ និងការគាំទ្ររដ្ឋបាលឃុំ សង្កាត់
- បញ្ចូល ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិទៅក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត ផអ៥ទី២ របស់អង្គភាព
- រៀបចំ និងដាក់ឱ្យអនុវត្តនូវសូចនាករនៃការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិសម្រាប់ត្រួតពិនិត្យ និងវាយម្លៃ និងរៀបចំរបាយការណ៍
- ត្រួតពិនិត្យ វាយតម្លៃ និងរៀបចំរបាយការណ៍ស្តីពីការអនុវត្តផែនការ និងគម្រោង កម្មវិធីនានាស្តីពីការងារគណនេយ្យភាពសង្គម
- សម្របសម្រួល និងសហការជាមួយអង្គភាពពាក់ព័ន្ធនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ដូចជាអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីក្នុងការសម្របសម្រួល និងណែនាំក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីយកចិត្តទុកដាក់ និងផ្តល់អាទិភាពក្នុងការវិភាជថវិការបស់ខ្លួនសម្រាប់គាំទ្រសកម្មភាពគណនេយ្យភាពសង្គម
- ពង្រឹងការសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម
- លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានស្តីពីការងារគណនេយ្យភាពសង្គមដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា

- រៀបចំ ដាក់ឱ្យអនុវត្ត និងគ្រប់គ្រងប្រព័ន្ធទិន្នន័យនានាសម្រាប់ការអនុវត្ត និងគ្រប់គ្រងការងារគណនេយ្យភាពសង្គម
- ពិនិត្យ និងធ្វើសមាហរណកម្មនៃការងារគណនេយ្យភាពសង្គមទៅក្នុងរចនាសម្ព័ន្ធ និងមុខងាររបស់អង្គភាព
- សហការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានារបស់ គ.ជ.អ.ប. ដើម្បីលើកកម្ពស់ការចូលរួម និងអនុវត្តការងារគណនេយ្យភាពសង្គម ដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរ អង្គភាពជំនាញ និងភាគីពាក់ព័ន្ធនានា រួមបញ្ចូល ការរៀបចំផែនការ និងការវិភាជថវិកាសម្រាប់គាំទ្រការងារគណនេយ្យភាពសង្គម។
- សិក្សាអំពីជម្រើសសមស្រប ដើម្បីដាក់ចេញនូវលិខិតបទដ្ឋានក្នុងការធ្វើសមាហរណកម្មរចនាសម្ព័ន្ធ តួនាទី និងភារកិច្ច របស់ក្រុមការងារគណនេយ្យភាពសង្គមរាជធានី ខេត្ត ក្រុមការងារគណនេយ្យភាពសង្គមក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការ ផ.ស.រ.គ ទៅក្នុងរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់។

សកម្មភាពជាអាទិភាព ១.៣. ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពិនិត្យ និងកំណត់មន្ត្រីបង្គោលការងារគណនេយ្យភាពសង្គមក្នុងចំណោមសមាជិកក្រុមការងារអនុវត្ត ផអ៥ទី២ និងពង្រឹងសមត្ថភាពអំពីការងារគណនេយ្យភាពសង្គម និងការងារពាក់ព័ន្ធផ្សេងទៀតឱ្យបានសមស្រប
- រៀបចំ និងបញ្ចូលការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត ផអទី២
- ពង្រឹងការអនុវត្តការងារគណនេយ្យភាពសង្គម ដើម្បីលើកកម្ពស់ការផ្តល់សេវារដ្ឋបាល សេវាសុខភាព សេវាអប់រំកម្រិតបឋមសិក្សា និងសេវាពាក់ព័ន្ធផ្សេងទៀត
- រៀបចំ និងដាក់ចេញលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា ដែលពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម ដូចជាសេចក្តីណែនាំអំពីស្តង់ដាសេវា ការផ្តល់សេវា សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវា
- អភិវឌ្ឍសមត្ថភាព ត្រួតពិនិត្យ និងគាំទ្រអង្គភាពផ្តល់សេវា និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីស្តង់ដាសេវា ការផ្តល់សេវា និងការងារពាក់ព័ន្ធផ្សេងទៀត
- ពង្រឹងការសម្របសម្រួល និងសហការជាមួយអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម
- សិក្សា និងកំណត់ប្រភេទសេវាបន្ថែមសម្រាប់បញ្ចូលក្នុងការងារគណនេយ្យភាពសង្គមនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

សកម្មភាពជាអាទិភាព ១.៤. ៖ សាលាជាតិរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សហការជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីរៀបចំ និងបញ្ចូលប្រធានបទនៃការងារគណនេយ្យភាពសង្គមក្នុងកម្មវិធីសិក្សារបស់សាលាជាតិ
- សម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលនានាក្នុងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសរដ្ឋបាលឃុំ សង្កាត់ ដើម្បីឱ្យអនុវត្តការងារគណនេយ្យភាពសង្គមមានប្រសិទ្ធភាព
- បញ្ចូលប្រធានបទនៃការងារគណនេយ្យភាពសង្គមក្នុងវគ្គបណ្តុះបណ្តាល និងកម្មវិធីសិក្សានានា រួមបញ្ចូលការសិក្សាតាមប្រព័ន្ធអនឡាញរបស់សាលាជាតិ។

សកម្មភាពជាអាទិភាព ១.៥. ៖ មន្ទីរ អង្គភាពជំនាញថ្នាក់រាជធានី ខេត្ត

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពិនិត្យ និងកំណត់មន្ត្រីបង្គោលការងារគណនេយ្យភាពសង្គម ព្រមទាំងពង្រឹងសមត្ថភាពអំពីការងារគណនេយ្យភាពសង្គម និងការងារពាក់ព័ន្ធផ្សេងទៀតឱ្យបានសមស្រប
- រៀបចំ និងបញ្ចូលសកម្មភាពនៃការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្តីពីការអនុវត្តកជទី២
- ពង្រឹងការអភិវឌ្ឍសមត្ថភាព ការត្រួតពិនិត្យ និងការគាំទ្រដល់អង្គភាពផ្តល់សេវានៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- សម្របសម្រួល សហការ និងគាំទ្រក្រុមការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត និងក្រុមការងារគណនេយ្យភាពសង្គមថ្នាក់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងគណៈកម្មការធិការ ផ.ស.រ.គ. ក្នុងការរៀបចំ និងអនុវត្តការងារគនេយ្យភាពសង្គម
- ពិនិត្យ និងធ្វើសមាហរណកម្មរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ក្រុមការងារគណនេយ្យភាពសង្គមរាជធានី ខេត្តទៅក្នុងរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់មន្ទីរ អង្គភាព ស្របតាមការណែនាំរបស់ថ្នាក់ជាតិ។

សកម្មភាពជាអាទិភាព ១.៦. ៖ រដ្ឋបាលរាជធានី ខេត្ត

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- អភិវឌ្ឍសមត្ថភាព និងគាំទ្រក្រុមការងារគណនេយ្យភាពសង្គមក្រុង ស្រុក ខណ្ឌក្នុងការអភិវឌ្ឍសមត្ថភាព ត្រួតពិនិត្យ និងគាំទ្រគណៈកម្មាធិការ ផ.ស.រ.គ. ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម
- ពង្រឹងសមត្ថភាពសមាជិកក្រុមការងារគណនេយ្យភាពសង្គមរាជធានី ខេត្ត ជាប្រចាំ
- រៀបចំ និងអនុវត្ត ផ.ស.ថ. ស្តីពីការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត
- សម្របសម្រួល និងបញ្ចូលសកម្មភាពស្តីពីការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្តី

ពីការអនុវត្ត កជទី២ របស់រដ្ឋបាលរាជធានី ខេត្ត
- ត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍ស្ដីពីការអនុវត្ត ផ.ស.ថ. ស្ដីពីការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត
- សម្របសម្រួល សហការជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលនានា ដែលសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ និងការងារគណនេយ្យភាពសង្គម
- ពិនិត្យ និងធ្វើសមាហរណកម្មរចនាសម្ព័ន្ធ តួនាទី និងភារកិច្ច របស់ក្រុមការងារគណនេយ្យភាពសង្គមរាជធានី ខេត្តទៅក្នុងរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អង្គភាពនៃរដ្ឋបាលរាជធានី ខេត្ត ស្របតាមការណែនាំរបស់ថ្នាក់ជាតិ។

សកម្មភាពជាអាទិភាព ១.៧. ៖ រដ្ឋបាលក្រុង ស្រុក ខណ្ឌ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ត្រួតពិនិត្យ អភិវឌ្ឍសមត្ថភាព និងគាំទ្រគណៈកម្មាធិការ ផ.ស.រ.គ. ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ដូចជាការអនុវត្តសៀវភៅណែនាំប្រតិបត្តិស្ដីពីការងារគណនេយ្យភាពសង្គម ការប្រើប្រាស់ និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យនានាពាក់ព័ន្ធនឹងគណនេយ្យភាបសង្គម ការផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ...
- អភិវឌ្ឍសមត្ថភាព និងគាំទ្រសមាជិកក្រុមការងារគណនេយ្យភាពសង្គមក្រុង ស្រុក ខណ្ឌ
- រៀបចំ និងអនុវត្ត ផ.ស.ថ. ស្ដីពីការងារគណនេយ្យភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ
- សម្របសម្រួល និងបញ្ចូលសកម្មភាពស្ដីពីការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្ដីពីការអនុវត្ត កជទី២ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍ស្ដីពីការអនុវត្ត ផ.ស.ថ. ស្ដីពីការងារគណនេយ្យភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ
- ពង្រឹងការកិច្ចសហការ និងចូលរួមរបស់ការិយាល័យ និងអង្គភាពជំនាញពាក់ព័ន្ធក្នុងការងារគណនេយ្យភាពសង្គម ដូចជាកំណត់មន្ត្រីបង្គោលទទួលបន្ទុកការងារគណនេយ្យភាពសង្គម កិច្ចសហការជាមួយក្រុមការងារគណនេយ្យភាពសង្គម ការបណ្ដុះបណ្ដាល...
- សម្របសម្រួល សហការជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលនានា ដែលសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ និងការងារគណនេយ្យភាពសង្គម
- ពិនិត្យ និងធ្វើសមាហរណកម្មរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ក្រុមការងារគណនេយ្យភាពសង្គមក្រុង ស្រុក ខណ្ឌទៅក្នុងរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អង្គភាពនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមការណែនាំរបស់ថ្នាក់ជាតិ។

សកម្មភាពជាអាទិភាព ១.៨. ៖ រដ្ឋបាលឃុំ សង្កាត់

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ពង្រឹងការរៀបចំ ផ.ស.រ.គ. តាមរយៈដំណើរការតម្រឹមការងារគណនេយ្យភាពសង្គមក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ពិនិត្យ និងវិភាជថវិកាសម្រាប់គាំទ្រសកម្មភាពនានានៃ ផ.ស.រ.គ. និងប្រតិបត្តិការនានានៃការងារគណនេយ្យភាពសង្គម
- រៀបចំ និងអនុវត្ត ផ.ស.ថ. ស្តីពីការងារគណនេយ្យភាពសង្គមថ្នាក់ឃុំ សង្កាត់
- ពិនិត្យ និងបញ្ចូលប្រតិបត្តិការ និងសកម្មភាពនានាស្តីពីការងារគណនេយ្យភាពសង្គមក្នុងគម្រោងថវិការបស់ឃុំ សង្កាត់
- លើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងារ និងការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋស្របតាមស្តង់ដានៃការផ្តល់សេវា និងសេចក្តីណែនាំនៃការងារគណនេយ្យភាពសង្គម
- ត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍ស្តីពីការអនុវត្ត ផ.ស.ថ. ស្តីពីការងារគណនេយ្យភាពសង្គមថ្នាក់ឃុំ សង្កាត់ រួមបញ្ចូល ផ.ស.រ.គ.
- សម្របសម្រួល សហការជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលនានា ដែលសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ និងការងារគណនេយ្យភាពសង្គម
- សម្របសម្រួល សហការ និងអនុវត្តការជ្រើសរើស និងគ្រប់គ្រងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- ពង្រឹងការកិច្ចសហការ និងគាំទ្រអង្គការសហគមន៍មូលដ្ឋាននានា ដើម្បីលើកកម្ពស់ការចូលរួម និងការគាំទ្ររបស់អង្គការទាំងនោះក្នុងការងារគណនេយ្យភាពសង្គម រួមបញ្ចូលការបំពេញតួនាទីជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- ពិនិត្យ និងធ្វើសមាហរណកម្មរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចនៃគណៈកម្មាធិការ ផ.ស.រ.គ. ទៅក្នុងរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់យន្តការនានានៃរដ្ឋបាលឃុំ សង្កាត់ ស្របតាមការណែនាំរបស់ថ្នាក់ជាតិ។

សកម្មភាពជាអាទិភាព ១.៩. ៖ មណ្ឌលសុខភាព និងសាលាបឋមសិក្សា

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- លើកកម្ពស់ការផ្សព្វផ្សាយ I4Cs អំពីស្តង់ដាសេវា ការផ្តល់សេវា និងលទ្ធផលនៃការបំពេញការងាររបស់អង្គភាពផ្តល់សេវាជូនប្រជាពលរដ្ឋ
- ចូលរួមការរៀបចំ និងអនុវត្ត ផ.ស.រ.គ. តាមដំណើរការតម្រឹមការងារគណនេយ្យភាពសង្គមក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ពិនិត្យ និងវិភាជថវិការបស់មណ្ឌលសុខភាព និងសាលាបឋមសិក្សាសម្រាប់គាំទ្រសកម្មភាពនានានៃ ផ.ស.រ.គ. និងប្រតិបត្តិការនានានៃការងារគណនេយ្យភាពសង្គមដែលស្របនឹងតួនាទី និងភារកិច្ចរបស់ខ្លួន

- លើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងារ និងការផ្ដល់សេវាជូនប្រជាពលរដ្ឋ ស្របតាមស្ដង់ដានៃការផ្ដល់សេវា និងសេចក្ដីណែនាំនៃការងារគណនេយ្យភាពសង្គម
- ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការបំពេញការងារ និងការផ្ដល់សេវាជូនប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព គុណភាព និងតម្លាភាពនៃការផ្ដល់សេវា
- ពិនិត្យ និងធ្វើសមាហរណកម្មនៃការងារគណនេយ្យភាពសង្គមទៅរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អង្គភាព ស្របតាមការណែនាំរបស់ថ្នាក់ជាតិ។

សកម្មភាពជាអាទិភាព ១.១០. ៖ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការនៅថ្នាក់ឃុំ សង្កាត់ ប្រកបដោយប្រសិទ្ធភាព និងឯករាជ្យភាព ស្របតាមដំណើការ និងនីតិវិធីដែលបានដាក់ចេញដោយ គ.ជ.អ.ប. ជាពិសេស ការផ្សព្វផ្សាយអំពី I4Cs ការសម្របសម្រួលកិច្ចប្រជុំវាយតម្លៃ និងដាក់ពិន្ទុរបស់ ប្រជាពលរដ្ឋលើលទ្ធផលនៃការផ្ដល់សេវា ការសម្របសម្រួល និងគាំទ្រកិច្ចប្រជុំឯកវិស័យ និងកិច្ចប្រជុំពហុវិស័យដើម្បីរៀបចំ ផ.ស.រ.គ. ជាដើម
- សម្របសម្រួល និងកិច្ចសហការជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ
- លើកកម្ពស់ការផ្សព្វផ្សាយអំពី I4Cs ឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋ និងសាធារណជននានា តាមមធ្យោបាយ វិធីសាស្ត្រ និងឧបករណ៍ផ្សេងៗ
- គាំទ្ររដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាព ដូចជាការការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្ដីពីការងារគណនេយ្យភាពសង្គម ការផ្សព្វផ្សាយអំពី I4Cs ការរៀបចំនិងផលិតទិន្នន័យ Post-on ការរៀបចំ ផ.ស.រ.គ.
- ត្រួតពិនិត្យ វាយតម្លៃ និងរៀបចំរបាយការណ៍ស្ដីពីការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ
- ចូលរួមក្នុងដំណើរការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់។

សកម្មភាពជាអាទិភាព ១.១១. ៖ បណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ដឹកនាំ និងសម្របសម្រួលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ
- រៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្ដីពីការអនុវត្តភារកិច្ចរបស់ខ្លួន
- ប្រាស្រ័យទាក់ទង សម្របសម្រួល និងសហការរវាងបណ្ដាញ CAF ថ្នាក់ជាតិ ថ្នាក់រាជ

ធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ

- សម្របសម្រួល កិច្ចសហការ និងការគាំទ្ររដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាល ក្រុង ស្រុក ខណ្ឌក្នុងការគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ក៏ដូចជាការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ
- អភិវឌ្ឍសមត្ថភាព ត្រួតពិនិត្យ និងគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- គាំទ្រ និងចូលរួមក្នុងដំណើរការជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- សហការជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងការគ្រប់គ្រងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដើម្បីធានាការបំពេញការងារប្រកបដោយប្រសិទ្ធភាព ឯករាជ្យភាព និងគណនេយ្យភាព
- លើកកម្ពស់ការកៀរគរធនធានពីប្រភពនានា សម្រាប់ការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ និងការងារគណនេយ្យភាពសង្គមជាទូទៅ។

សកម្មភាពជាអាទិភាព ១.១២. ៖ អង្គការសង្គមស៊ីវិល រួមបញ្ចូលអង្គការសហគមន៍មូលដ្ឋាន

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ប្រាស្រ័យទាក់ទង សហការ និងចូលរួមអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ជាពិសេសការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ
- ចូលរួមការសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការនៅថ្នាក់ឃុំ សង្កាត់ ស្របតាមដំណើរការ និងនីតិវិធីដែលបានដាក់ចេញដោយ គ.ជ.អ.ប.
- សម្របសម្រួល កិច្ចសហការ និងការគាំទ្រឃុំ សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ
- សហការ និងគាំទ្រឃុំ សង្កាត់ក្នុងការជ្រើសរើស ការគ្រប់គ្រង និងការបំពេញការងាររបស់អ្នកសម្របសម្រួលគណនៀ្យភាពសហគមន៍
- អភិវឌ្ឍសមត្ថភាព និងគាំទ្រអ្នកសម្របសម្រួលគណនៀ្យភាពសហគមន៍ និងបណ្ដាញអ្នកសម្របសម្រួលគណនៀ្យភាពសហគមន៍នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ
- សហការ និងកៀរគរធនធាននានា ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការនៅថ្នាក់ឃុំ សង្កាត់
- ពង្រឹងការត្រួតពិនិត្យ ការវាយតម្លៃ និងការរៀបចំរបាយការណ៍ស្ដីពីការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ។

សកម្មភាពជាអាទិភាព ១.១៣. ៖ ប្រជាពលរដ្ឋ និងសាធារណជន

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ចូលរួមក្នុងសកម្មភាពនានានៃការអប់រំ និងផ្សព្វផ្សាយអំពី I4Cs និងការងារគណនេយ្យ

ភាពសង្គម ដែលអនុវត្តដោយអង្គភាពផ្តល់សេវា និងអ្នកពាក់ព័ន្ធនានា

- ចូលរួមដោយស្ម័គ្រចិត្តក្នុងការបំពេញតួនាទី និងភារកិច្ចជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- ចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្តក្នុងដំណើរការបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់អង្គភាពផ្តល់សេវានៅថ្នាក់ឃុំ សង្កាត់ តាមរយៈការអនុវត្តការងារគណនេយ្យភាពសង្គម ជាពិសេសការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ ផ.ស.រ.គ.។

យុទ្ធសាស្ត្រទី ២ ៖ ការអភិវឌ្ឍសមត្ថភាពអង្គភាពផ្តល់សេវា និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដើម្បីអនុវត្តការងារគណនេយ្យភាពសង្គម ប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ជាអ្នកទទួលខុសត្រូវជារួមក្នុងការអភិវឌ្ឍសមត្ថភាពអំពីការងារគណនេយ្យភាពសង្គមទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ដោយសហការជិតស្និទ្ធជាមួយស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងគ្រឹះស្ថានសិក្សានានា ដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវា និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ សម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព។ ក្នុងន័យនេះ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងភាគីពាក់ព័ន្ធនានាដែលទទួលខុសត្រូវក្នុងការអភិវឌ្ឍសមត្ថភាព និងគាំទ្រអង្គភាពផ្តល់សេវា និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ត្រូវមានសមត្ថភាព និងជំនាញសមស្រប ដើម្បីធានាការអភិវឌ្ឍសមត្ថភាព និងការគាំទ្រអង្គភាពផ្តល់សេវាថ្នាក់ឃុំ សង្កាត់ និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព។

យុទ្ធសាស្ត្រនេះផ្តោតសំខាន់លើការអភិវឌ្ឍសមត្ថភាពអង្គភាពផ្តល់សេវា និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅថ្នាក់ឃុំ សង្កាត់ ដើម្បីធានាការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព។

ដើម្បីសម្រេចយុទ្ធសាស្ត្រនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានរៀបរាប់ដូចខាងក្រោម ៖

សកម្មភាពជាអាទិភាព ២.១. ៖ រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្តីពីការងារគណនេយ្យភាពសង្គម ដោយអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប.

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សម្របសម្រួល រៀបចំ និងអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំស្តីពីការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីទទួលខុសត្រូវការងារគណនេយ្យភាពសង្គមនៃអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន ក្រុមការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់រាជធានី ខេត្ត និងអ្នកពាក់ព័ន្ធនានាអំពីការងារ

គណនេយ្យភាពសង្គម និងប្រធានបទពាក់ព័ន្ធផ្សេងទៀត ដោយសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា

- សហការជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋានក្នុងការកំណត់ និងបញ្ចូលប្រធានបទនៃការងារគណនេយ្យភាពសង្គមក្នុងផែនការបណ្តុះបណ្តាលប្រចាំឆ្នាំរបស់សាលាជាតិ
- លើកកម្ពស់ការបង្វឹក និងសិក្សារៀនសូត្រពីគ្នាទៅវិញទៅមករវាងមន្ត្រី
- ចុះត្រួតពិនិត្យ និងគាំទ្រជាប្រចាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសង្គមក្នុងការសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គម។

សកម្មភាពជាអាទិភាព ២.២. ៖ រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្តីពីការងារគណនេយ្យភាពសង្គម ដោយក្រុមការងារគណនេយ្យភាពសង្គមរាជធានី ខេត្ត

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សម្របសម្រួល រៀបចំ និងអនុវត្តផែនការប្រចាំឆ្នាំស្តីពីការអភិវឌ្ឍសមត្ថភាពដល់សមាជិកក្រុមការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត ក្រុមការងារគណនេយ្យភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធនានា អំពីការងារគណនេយ្យភាពសង្គម និងប្រធានបទពាក់ព័ន្ធផ្សេងទៀត ដោយសហការជិតស្និទ្ធជាមួយមន្ទីរ អង្គភាពជំនាញ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា
- ពង្រឹងការបង្វឹក និងការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមករវាងសមាជិកនៃក្រុមការងារគណនេយ្យភាពសង្គមរាជធានី ខេត្ត និងរវាងក្រុមការងារគណនេយ្យភាពសង្គមរាជធានីខេត្តក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម
- ចុះត្រួតពិនិត្យ និងគាំទ្រជាប្រចាំដល់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ និងអង្គភាពផ្តល់សេវាក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម។

សកម្មភាពជាអាទិភាព ២.៣. ៖ រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្តីពីការងារគណនេយ្យភាពសង្គម ដោយក្រុមការងារគណនេយ្យភាពសង្គមក្រុង ស្រុក ខណ្ឌ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សម្របសម្រួល រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំដល់សមាជិកក្រុមការងារ គណៈកម្មាធិការ ផ.ស.រ.គ. អង្គភាពផ្តល់សេវា អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការសង្គមស៊ីវិល អង្គការសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀតអំពីការងារគណនេយ្យភាពសង្គម និងប្រធានបទពាក់ព័ន្ធផ្សេងទៀត ដោយសហការជិតស្និទ្ធជាមួយអង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា

- ពង្រឹងការបង្វឹក និងការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមករវាងសមាជិកនៃក្រុមការងារគណនេយ្យភាពសង្គមក្រុង ស្រុក ខណ្ឌ និងរវាងក្រុមការងារគណនេយ្យភាពសង្គមនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម
- ចុះត្រួតពិនិត្យ និងគាំទ្រជាប្រចាំដល់រដ្ឋបាលឃុំ សង្កាត់ និងអង្គភាពផ្តល់សេវានានាក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម។

សកម្មភាពជាអាទិភាព ២.៤. ៖ រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្តីពីការងារគណនេយ្យភាពសង្គម ដោយគណៈកម្មាធិការ ផ.ស.រ.គ.

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សម្របសម្រួល រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំដល់គណៈកម្មាធិការ ផ.ស.រ.គ. អង្គការសហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀតអំពីការងារគណនេយ្យភាពសង្គម និងប្រធានបទពាក់ព័ន្ធផ្សេងទៀត ដោយសហការជាមួយក្រុមការងារគណនេយ្យភាពសង្គមក្រុង ស្រុក ខណ្ឌ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងភាគីពាក់ព័ន្ធនានា
- លើកកម្ពស់ការបង្វឹក និងការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមករវាងសមាជិកនៃគណៈកម្មាធិការ ផ.ស.រ.គ.
- លើកកម្ពស់ការសិក្សារៀនសូត្រ តាមរយៈការសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គម និងការផ្តល់សេវានានា និងត្រួតពិនិត្យការអនុវត្ត ផ.ស.រ.គ.។

សកម្មភាពជាអាទិភាព ២.៥. ៖ រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្តីពីការងារគណនេយ្យភាពសង្គម ដោយអង្គភាពផ្តល់សេវា

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សម្របសម្រួល រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំដល់មន្ត្រីនៃអង្គភាពផ្តល់សេវា អង្គការសហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀតអំពីការងារគណនេយ្យភាពសង្គម និងប្រធានបទពាក់ព័ន្ធផ្សេងទៀត ដោយសការជាមួយក្រុមការងារគណនេយ្យភាពសង្គមក្រុង ស្រុក ខណ្ឌ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងភាគីពាក់ព័ន្ធនានា
- លើកកម្ពស់ការបង្វឹក និងការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមករវាងមន្ត្រី
- លើកកម្ពស់ការសិក្សារៀនសូត្រ តាមរយៈការសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គម និងការផ្តល់សេវានានា
- ចុះត្រួតពិនិត្យ និងផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាអំពីការងារគណនេយ្យភាពសង្គម និងការផ្តល់សេវា។

សកម្មភាពជាអាទិភាព ២.៦. ៖ រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្ដីពីការងារគណនេយ្យភាពសង្គម ដោយបណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់រាជធានី ខេត្ត

បណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់រាជធានី ខេត្ត ត្រូវបានបង្កើតឡើងក្នុងគោលបំណងដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពបណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីបំពេញ តួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងឯករាជ្យភាព។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សម្របសម្រួល រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពជាប្រចាំដល់បណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ
- លើកកម្ពស់ការបង្វឹក និងសិក្សារៀនសូត្រពីគ្នាទៅវិញទៅមករវាងសមាជិកបណ្ដាញក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន
- ត្រួតពិនិត្យ និងផ្ដល់ការគាំទ្រជាប្រចាំដល់បណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។
- រៀបចំការឆ្លុះបញ្ចាំង និងសិក្សារៀនសូត្រអំពីការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។

សកម្មភាពជាអាទិភាព ២.៧. ៖ រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្ដីពីការងារគណនេយ្យភាពសង្គម ដោយបណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ

បណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើងក្នុងគោលបំណងដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ឃុំ សង្កាត់ ដើម្បីបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងឯករាជ្យភាព។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- សម្របសម្រួល រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពជាប្រចាំដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ឃុំ សង្កាត់
- លើកកម្ពស់ការបង្វឹក និងសិក្សារៀនសូត្រពីគ្នាទៅវិញទៅមករវាងសមាជិកបណ្ដាញក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន
- ត្រួតពិនិត្យ និងផ្ដល់ការគាំទ្រជាប្រចាំដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- រៀបចំការឆ្លុះបញ្ចាំង និងសិក្សារៀនសូត្រអំពីការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។

សកម្មភាពជាអាទិភាព ២.៨. ៖ រៀបចំ និងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពស្ដីពីការងារគណនេយ្យភាពសង្គម ដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- កំណត់ និងបញ្ចូលប្រធានបទការងារគណនេយ្យភាពសង្គមក្នុងផែនការបណ្តុះបណ្តាលប្រចាំឆ្នាំរបស់សាលាជាតិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប.
- រៀបចំ និងសម្របសម្រួលវគ្គបណ្តុះបណ្តាលអំពីការងារគណនេយ្យភាពសង្គម ដោយសហការជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា។

សកម្មភាពជាអាទិភាព ២.៩. ៖ ចងក្រង និងចែករំលែកពីមេរៀន បទពិសោធន៍ល្អៗស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ដោយអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប.

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំ និងដាក់ចេញនូវលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់មេរៀន និងបទពិសោធន៍ល្អៗ នៃការអនុវត្តការងារគណនេយ្យភាពសង្គម
- សិក្សា កំណត់ និងរៀបចំចងក្រងជាមេរៀន និងបទពិសោធន៍ល្អៗ ផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់
- លើកកម្ពស់ការផ្សព្វផ្សាយអំពីមេរៀន និងបទពិសោធន៍ល្អៗដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវា និងភាគីពាក់ព័ន្ធនានា
- ពង្រឹងការត្រួតពិនិត្យ និងគាំទ្រការអនុវត្តមេរៀន និងបទពិសោធន៍ល្អៗ។

សកម្មភាពជាអាទិភាព ២.១០. ៖ រៀបចំ និងសម្របសម្រួលកម្មវិធីផ្លាស់ប្តូរបទពិសោធន៍រវាងគ្នាទៅវិញទៅមករវាងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការអនុវត្តការងារគណនេយ្យភាពសង្គម

សកម្មភាពនេះ ផ្តោតលើការលើកកម្ពស់ប្រសិទ្ធភាព គុណភាព តម្លាភាព និងគណនេយ្យភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គម ការបំពេញការងារ និងការផ្តល់សេវា តាមរយៈការចែករំលែកមេរៀន និងបទពិសោធន៍នានា ដែលបានអនុវត្តដោយជោគជ័យ រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវា។

ដើម្បីសម្រេចបាននូវសកម្មភាពនេះ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំ និងដាក់ចេញនូវសេចក្តីណែនាំស្តីពីវិធីសាស្ត្រសម្រាប់ផ្លាស់ប្តូរបទពិសោធន៍ និងរៀនសូត្រពីគ្នាទៅវិញទៅមករវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវា
- ផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវា និងភាគីពាក់ព័ន្ធនានាអំពីសេចក្តីណែនាំស្តីពីវិធីសាស្ត្រសម្រាប់ផ្លាស់ប្តូរបទពិសោធន៍ និង រៀនសូត្រពីគ្នាទៅវិញទៅមក

- ពង្រឹងការរៀបចំ និងអនុវត្តកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ និងរៀនសូត្រពីគ្នាទៅវិញទៅមក
- ត្រួតពិនិត្យ និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវាក្នុងការអនុវត្តកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ និងរៀនសូត្រពីគ្នាទៅវិញទៅមក។

សកម្មភាពជាអាទិភាព ២.១១. ៖ លើកកម្ពស់ការសិក្សាតាមប្រព័ន្ធអនឡាញអំពីការងារគណនេយ្យភាពសង្គម តាមថ្នាលប្រព័ន្ធគណនេយ្យភាពសង្គមរបស់ គ.ជ.អ.ប.

ថ្នាលប្រព័ន្ធគណនេយ្យភាពសង្គម បានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ដោយ គ.ជ.អ.ប. ក្នុងឆ្នាំ ២០២៦ ក្នុងគោលបំណងលើកកម្ពស់ការផ្សព្វផ្សាយ និងការសិក្សារៀនសូត្រអំពីការងារគណនេយ្យភាពសង្គមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសាធារណជននានា។

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- លេខាធិការដ្ឋាន គ.ជ.អ.ប. ផ្សព្វផ្សាយអំពីថ្នាលប្រព័ន្ធគណនេយ្យភាពសង្គមដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសាធារសាធារណជននានា និងបណ្តុះបណ្តាលអំពីការប្រើប្រាស់សៀវភៅណែនាំស្តីពីថ្នាលប្រព័ន្ធគណនេយ្យភាពសង្គមដល់ថ្នាក់រាជធានី ខេត្ត
- រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំវគ្គបណ្តុះបណ្តាលអំពីការប្រើប្រាស់សៀវភៅណែនាំស្តីពីថ្នាលប្រព័ន្ធគណនេយ្យភាពសង្គមដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អង្គភាពផ្តល់សេវា និងភាគីពាក់ព័ន្ធនានា
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវត្រួតពិនិត្យ និងគាំទ្ររដ្ឋបាលឃុំ សង្កាត់ក្នុងការសិក្សាអំពីការងារគណនេយ្យភាពសង្គម តាមរយៈថ្នាលប្រព័ន្ធគណនេយ្យភាពសង្គម។

យុទ្ធសាស្ត្រទី៣ ៖ ការរៀបចំផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ដើម្បីគាំទ្រការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់

ការលើកកម្ពស់ការងារគណនេយ្យភាពសង្គម គឺជាផ្នែកមួយនៃ កជទី២។ ក្នុងន័យនេះ សកម្មភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងឆ្នាំនីមួយៗ ត្រូវបញ្ចូលក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត កជទី២ របស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត។

ជារៀងរាល់ឆ្នាំ ក្រសួង ស្ថាប័នចំនួន ២៣ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទូទាំងប្រទេសបានចូលរួមយ៉ាងសកម្មភាពក្នុងការអនុវត្ត កជទី២ តាមរយៈការរៀបចំ និងអនុវត្ត ផ.ស.ថ. ស្តីពីការអនុវត្ត កជទី២ ស្របតាមនីតិវិធី និងការណែនាំរបស់ គ.ជ.អ.ប.។ អាស្រ័យហេតុនេះ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធទាំងអស់ ត្រូវធានាថា ការងារគណនេយ្យភាពសង្គម ត្រូវបានបញ្ចូលជាផ្នែកមួយនៃ ផ.ស.ថ. ស្តីពីការអនុវត្ត កជទី២ ស្របតាមវិសាលភាពគ្របដណ្តប់ និងដំណាក់កាលនៃការអនុវត្តការងារគណនេយ្យភាពសង្គមដែលពាក់ព័ន្ធនឹងក្រសួង ស្ថាប័ននីមួយៗ។

យុទ្ធសាស្ត្រនេះផ្តោតលើការរៀបចំ និងបញ្ចូលការងារគណនេយ្យភាពសង្គមទៅក្នុង ផ.ស.ថ. នៃការអនុវត្ត កជទី២ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងដំណើរការនៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់។

ដើម្បីសម្រេចយុទ្ធសាស្ត្រនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានរៀបរាប់ដូចខាងក្រោម ៖

សកម្មភាពជាអាទិភាព ៣.១. ៖ រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមរបស់អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីអភិវឌ្ឍសមត្ថភាព ត្រួតពិនិត្យ និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ដើម្បីគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលរដ្ឋបាលឃុំ សង្កាត់ រួមមានសកម្មភាព ៖
    - ការរៀបចំកិច្ចប្រជុំ និងទស្សនកិច្ចសិក្សានានារបស់ គ.គ.អ.ស.
    - ការអភិវឌ្ឍសមត្ថភាព ការត្រួតពិនិត្យតាមដាន និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ
    - ការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា
    - ការសិក្សា និងការវាយតម្លៃនានា
    - ការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា
    - ការសហការ និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍នានា
    - ការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យនានាស្តីពីការងារគណនេយ្យភាពសង្គម
    - ការសម្របសម្រួល និងការគាំទ្រផ្នែកប្រតិបត្តិការនានា
    - សកម្មភាពពាក់ព័ន្ធផ្សេងទៀត
- បញ្ចូលផែនការនេះទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន និងផែនការយុទ្ធសាស្ត្រថវិការបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។

សកម្មភាពជាអាទិភាព ៣.២. ៖ រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្តការងារ គណនេយ្យភាពសង្គមរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- ពិភាក្សា និងកំណត់សកម្មភាពនានាដែលពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមក្នុងការអភិវឌ្ឍសមត្ថភាព និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលរដ្ឋបាលឃុំ សង្កាត់ ដើម្បីអនុវត្តការងារនេះប្រកបដោយប្រសិទ្ធភាព មានដូចជា ៖
    - ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ អង្គភាពជំនាញនានាអំពីស្តង់ដាសេវា និងការផ្តល់សេវា

- ការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋាន សេចក្តីណែនាំ ស្តង់ដា ព័ត៌មាន និងឧបករណ៍នានាស្តីពីការផ្តល់សេវា
- ការត្រួតពិនិត្យតាមដាន និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ អង្គភាពជំនាញនានាក្នុងការផ្តល់សេវា។ល។

– បញ្ចូលសកម្មភាពនៃការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត កជទី២ និងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន។

សកម្មភាពជាអាទិភាព ៣.៣. ៖ រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្តការងារ គណនេយ្យភាពសង្គមរបស់មន្ទីរ អង្គភាពពាក់ព័ន្ធថ្នាក់រាជធានី ខេត្ត

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

– ពិភាក្សា និងកំណត់សកម្មភាពនានាក្នុងការអភិវឌ្ឍសមត្ថភាព និងគាំទ្ររដ្ឋបាលរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ដូចជា ៖
  - ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលឃុំ សង្កាត់ និងអង្គភាពផ្តល់សេវានានាក្នុងការបំពេញការងារ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ
  - ការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋាន សេចក្តីណែនាំ ស្តង់ដា ព័ត៌មាន និងឧបករណ៍នានាស្តីពីការផ្តល់សេវា
  - ការត្រួតពិនិត្យ និងគាំទ្រអង្គភាពផ្តល់សេវានានាក្នុងការផ្តល់សេវាក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ
  - ការគាំទ្រគម្រោង សកម្មភាពក្នុង ផ.ស.រ.គ.។ល។

– បញ្ចូលសកម្មភាពនៃការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត កជទី២ និងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន។

សកម្មភាពជាអាទិភាព ៣.៤. ៖ រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការងារអនុវត្តការងារ គណនេយ្យភាពសង្គមរបស់ក្រុមការងារអនុវត្តការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

– កំណត់សកម្មភាព និងប្រតិបត្តិការនានានៃការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត រួមបញ្ចូលការគាំទ្រក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដូចជា ៖
  - ការរៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំស្តីពីការងារគណនេយ្យភាពសង្គម
  - ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលឃុំ សង្កាត់អំពីការងារគណនេយ្យភាពសង្គម

- o ការចុះត្រួតពិនិត្យ និងគាំទ្ររដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម
- o សកម្មភាព និងកិច្ចប្រតិបត្តិការនានា ដែលត្រូវអនុវត្តដោយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅថ្នាក់រាជធានី ខេត្ត
- o ការគាំទ្រគម្រោង សកម្មភាពក្នុង ផ.ស.រ.គ.
- o សកម្មភាពពាក់ព័ន្ធផ្សេងទៀត

– បញ្ចូលសកម្មភាពនៃការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត កជទី២ និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

សកម្មភាពជាអាទិភាព ៣.៥. ៖ រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់រាជធានី ខេត្ត

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

– រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់បណ្តាញ ស្របតាមសេចក្តីណែនាំដែលបានកំណត់ រួមបញ្ចូលសកម្មភាពដូចជា ៖
  - o ការអភិវឌ្ឍសមត្ថភាពបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ
  - o ការរៀបចំកិច្ចប្រជុំប្រនានារបស់បណ្តាញ
  - o ការត្រួតពិនិត្យ និងគាំទ្របណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ
  - o ការគាំទ្រផ្នែកប្រតិបត្តិការនានារបស់បណ្តាញ។

– សម្របសម្រួល និងបញ្ចូលផែនការសកម្មភាពនេះក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត កជទី២ របស់រដ្ឋបាលរាជធានី ខេត្ត។

សកម្មភាពជាអាទិភាព ៣.៦. ៖ រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការងារអនុវត្តការងារ គណនេយ្យភាពសង្គមរបស់ក្រុមការងារអនុវត្តការងារគណនេយ្យភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

– កំណត់សកម្មភាព និងប្រតិបត្តិការនានានៃការងារគណនេយ្យភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ រួមបញ្ចូលការគាំទ្រឃុំ សង្កាត់ ដូចជា ៖
  - o ការរៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំស្តីពីការងារគណនេយ្យភាពសង្គម

- o ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលឃុំ សង្កាត់អំពីការងារគណនេយ្យភាពសង្គម
- o ការចុះត្រួតពិនិត្យ និងគាំទ្ររដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម
- o សកម្មភាព និងកិច្ចប្រតិបត្តិការនានា ដែលត្រូវអនុវត្តដោយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- o ការគាំទ្រគម្រោង សកម្មភាពក្នុង ផ.ស.រ.គ.
- o ការគាំទ្រគម្រោង សកម្មភាពក្នុង ផ.ស.រ.គ.
- o សកម្មភាពពាក់ព័ន្ធផ្សេងទៀត

– បញ្ចូលសកម្មភាពនៃការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត កជទី២ និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

សកម្មភាពជាអាទិភាព ៣.៧. ៖ រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការងារអនុវត្តការងារ គណនេយ្យភាពសង្គមរបស់បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

– រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់បណ្តាញ ស្របតាមសេចក្តីណែនាំដែលបានកំណត់ រួមបញ្ចូលសកម្មភាពដូចជា ៖
  - o ការអភិវឌ្ឍសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
  - o ការរៀបចំកិច្ចប្រជុំប្រនានារបស់បណ្តាញ
  - o ការត្រួតពិនិត្យ និងគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
  - o ការគាំទ្រផ្នែកប្រតិបត្តិការនានារបស់បណ្តាញ។

– សម្របសម្រួល និងបញ្ចូលផែនការសកម្មភាពនេះក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត កជទី២ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

សកម្មភាពជាអាទិភាព ៣.៨. ៖ រៀបចំផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមរបស់រដ្ឋបាលឃុំ សង្កាត់

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

– រៀបចំផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមរបស់រដ្ឋបាលឃុំ សង្កាត់ ស្របតាមសេចក្តីណែនាំ រួមបញ្ចូលសកម្មភាពសំខាន់ៗដូចជា ៖
  - o ការរៀបចំកិច្ចប្រជុំប្រចាំខែ និងប្រចាំឆ្នាំរបស់គណៈកម្មាធិការ គ.ស.រ.គ. ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការងារគណនេយ្យភាពសង្គម

    - o សកម្មភាពនានាពាក់ព័ន្ធនឹងដំណើរការរៀបចំ និងអនុវត្ត ផ.ស.រ.គ.
    - o សកម្មភាពនានាពាក់ព័ន្ធនឹងការរៀបចំ និងការផ្សព្វផ្សាយទិន្នន័យ និងព័ត៌មាននានាស្តីពីការងារគណនេយ្យភាពសង្គម ដូចជាការផលិត និងការផ្សព្វផ្សាយផ្ទាំងព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs)
    - o សកម្មភាព និងកិច្ចប្រតិបត្តិការនានាសម្រាប់គាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
    - o សកម្មភាពពាក់ព័ន្ធផ្សេងទៀត
- រៀបចំ ផ.ស.រ.គ. ស្របតាមដំណើរការ និងនីតិវិធីកំណត់
- បញ្ចូលផែនការសកម្មភាពក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់។

សកម្មភាពជាអាទិភាព ៣.៩. ៖ រៀបចំផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមរបស់មណ្ឌលសុខភាព និងសាលាបឋមសិក្សា

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- រៀបចំផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមរបស់មណ្ឌលសុខភាព និងសាលាបឋមសិក្សា រួមបញ្ចូលសកម្មភាពសំខាន់ៗដូចជា ៖
    - o ពង្រឹងការរៀបចំកិច្ចប្រជុំប្រចាំខែ និងប្រចាំឆ្នាំរបស់អង្គភាពផ្តល់សេវា ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការងារគណនេយ្យភាពសង្គម
    - o សកម្មភាពនានាពាក់ព័ន្ធនឹងដំណើរការរៀបចំ និងអនុវត្ត ផ.ស.រ.គ. ដូចជាការរៀបចំ និងផលិតទិន្នន័យស្តីពីលទ្ធផលការងារ ការវាយតម្លៃខ្លួនឯងអំពីលទ្ធផលនៃការផ្តល់សេវា ការរៀបចំកិច្ចប្រជុំរៀបចំ ផ.ស.រ.គ. តាមវិស័យ...
    - o សកម្មភាពនានាពាក់ព័ន្ធនឹងការរៀបចំ និងការផ្សព្វផ្សាយទិន្នន័យ និងព័ត៌មាននានាស្តីពីការងារគណនេយ្យភាពសង្គម ដូចជាការផលិត និងការផ្សព្វផ្សាយផ្ទាំងព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs)
    - o សកម្មភាពពាក់ព័ន្ធផ្សេងទៀត
- បញ្ចូលសកម្មភាពនៃការងារគណនេយ្យភាពសង្គមក្នុងផែនការ និងគម្រោងថវិកាប្រចាំឆ្នាំរបស់អង្គភាពផ្តល់សេវា។

សកម្មភាពជាអាទិភាព ៣.១០. ៖ រៀបចំ និងដាក់ឱ្យអនុវត្តនូវសៀវភៅណែនាំរួមស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់

សកម្មភាពនេះផ្តោតលើការរៀបចំ និងដាក់ឱ្យអនុវត្តនូវសៀវភៅណែនាំប្រតិបត្តិរួមមួយស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ សម្រាប់អនុវត្តនៅក្នុងឃុំ សង្កាត់ដែលមានការគាំទ្រពីអង្គការសង្គមស៊ីវិលក្នុងការអនុវត្តផ្នែកតម្រូវការ និងនៅក្នុងឃុំ សង្កាត់ដែលពុំមានការគាំទ្រ ពីអង្គការសង្គមស៊ីវិលក្នុងការអនុវត្តផ្នែកតម្រូវការ។

សកម្មភាពនេះ គឺជាការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- រៀបចំ និងដាក់ឱ្យអនុវត្តនូវសៀវភៅណែនាំប្រតិបត្តិស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមថ្នាក់ឃុំ សង្កាត់ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ សម្រាប់អនុវត្តនៅក្នុងឃុំ សង្កាត់ដែលមាន និងពុំមានការគាំទ្រពីអង្គការសង្គមស៊ីវិលក្នុងការអនុវត្តផ្នែកតម្រូវការ ដោយផ្អែកលើឯកសារសំខាន់ៗដូចខាងក្រោម ៖
  - o លទ្ធផលនៃការវាយតម្លៃលើការសាកល្បងស្តីពីការតម្រឹមនៃការងារគណនេយ្យភាពសង្គមក្នុងដំណើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់
  - o ឯកសារទស្សនទានស្តីពីការសាកល្បងស្តីពីការតម្រឹមនៃការងារគណនេយ្យភាពសង្គមក្នុងដំណើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់
  - o សៀវភៅណែនាំប្រតិបត្តិស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់
  - o សៀវភៅណែនាំប្រតិបត្តិស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ
  - o សេចក្តីណែនាំស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់។ល។
- រៀបចំការផ្សព្វផ្សាយ និងបណ្តុះបណ្តាលសៀវភៅណែនាំប្រតិបត្តិស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមថ្នាក់ឃុំ សង្កាត់ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការដល់ភាគីពាក់ព័ន្ធនានា ដើម្បីពង្រីកការអនុវត្ត
- លើកកម្ពស់ការអនុវត្តសៀវភៅណែនាំប្រតិបត្តិស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមថ្នាក់ឃុំ សង្កាត់ ដោយគម្រោង កម្មវិធីជាច់ដោយឡែកនានាដែលស្ថិតក្រោមការគ្រប់គ្រង និងសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។

### យុទ្ធសាស្ត្រទី៤ ៖ ការវិភាជថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម

យុទ្ធសាស្ត្រនេះផ្តោតលើការវិភាជថវិកា និងមូលនិធិរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រ ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម សំដៅពង្រឹងការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងនិរន្តរភាព។ ទន្ទឹមនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវលើកកម្ពស់កិច្ចសហការ និងការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីគាំទ្រការងារអនុវត្តការងារគណនេយ្យភាពសង្គម។

ដើម្បីសម្រេចបានយុទ្ធសាស្ត្រនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានរៀបរាប់ដូចខាងក្រោម ៖

#### សកម្មភាពជាអាទិភាព ៤.១. ៖ វិភាជថវិកាដើម្បីគាំទ្រ ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ដោយលេខាធិការដ្ឋាន គ.ជ.អ.ប.

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- ពិនិត្យ និងវិភាជថវិកាពីប្រចាំឆ្នាំរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីគាំទ្រសកម្មភាព និងកិច្ចប្រតិបត្តិការនានាដែលបានកំណត់ក្នុង ផ.ស.ថ. ស្ដីពីការអនុវត្តការងារគណនេយ្យភាពសង្គម ដែលបានរៀបចំ
- សហការ និងកៀគរធនធានពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដូចជា WB, ISD/GIZ, DFAT, WVI... ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម
- រៀបចំ និងបញ្ចូលថវិកាគាំទ្រការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្ដីពីការអនុវត្តផអ៥ទី២ និងផែនការយុទ្ធសាស្ត្រថវិការបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។

សកម្មភាពជាអាទិភាព ៤.២. ៖ វិភាជថវិកាដើម្បីគាំទ្រ ផ.ស.ថ. ស្ដីពីការអនុវត្តការងារគណនេយ្យភាពសង្គមដោយក្រសួង ស្ថាប័នពាក់ព័ន្ធ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- ពិនិត្យ និងវិភាជថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន ដើម្បីគាំទ្រសកម្មភាព និងប្រតិបត្តិការនានាដែលបានកំណត់ក្នុង ផ.ស.ថ. សម្រាប់ការងារគណនេយ្យភាពសង្គម
- សហការ និងកៀគរធនធានពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម
- រៀបចំ និងបញ្ចូលថវិកាគាំទ្រការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្ដីពីការអនុវត្តផអ៥ទី២ និងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន។

សកម្មភាពជាអាទិភាព ៤.៣. ៖ វិភាជថវិកាដើម្បីគាំទ្រ ផ.ស.ថ. ស្ដីពីការអនុវត្តការងារគណនេយ្យភាពសង្គមដោយរដ្ឋបាលរាជធានី ខេត្ត និងខណ្ឌ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- ពិនិត្យ និងបែងចែកថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត និងខណ្ឌសម្រាប់ កជទី២ ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម
- ពិនិត្យ និងបែងចែកថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត និងខណ្ឌសម្រាប់សេវាសង្គម (យ៉ាងតិច១០% ធៀបនឹងថវិកាអភិវឌ្ឍ/ ថវិកាគុណប្រយោជន៍ប្រចាំឆ្នាំ ស្របតាមការណែនាំរបស់ក្រសួងមហាផ្ទៃ) ដើម្បីគាំទ្រការងារ គណនេយ្យភាពសង្គម រួមបញ្ចូលថវិកាសម្រាប់គាំទ្រគម្រោង សកម្មភាពនៃ ផ.ស.រ.គ.
- ពិនិត្យ និងវិភាជថវិកាពីថវិកាអភិវឌ្ឍប្រចាំឆ្នាំរបស់រាជធានី ខេត្ត និងខណ្ឌ ដើម្បីគាំទ្រសកម្មភាព និងកិច្ចប្រតិបត្តិការនានាដែលបានកំណត់ក្នុង ផ.ស.ថ. ស្ដីពីការអនុវត្តការងារគណនេយ្យភាពសង្គម រួមបញ្ចូលថវិកាសម្រាប់គាំទ្រគម្រោង សកម្មភាពនៃ ផ.ស.រ.គ. ផ្អែកតាមគោលការណ៍ និងសេចក្ដីណែនាំដែលបានកំណត់
- សហការ និងកៀគរធនធានពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម

- រៀបចំ និងបញ្ចូលថវិកាគាំទ្រការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត ផអ៥ទី២ និងគម្រោងថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត និងខណ្ឌ។

សកម្មភាពជាអាទិភាព ៤.៤. ៖ វិភាជថវិកាដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម ដោយមន្ទីរ
អង្គភាពជំនាញពាក់ព័ន្ធថ្នាក់រាជធានី ខេត្ត

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- ពិនិត្យ និងវិភាជថវិកាពីប្រចាំឆ្នាំរបស់មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ ដើម្បីគាំទ្រសកម្មភាព និងកិច្ចប្រតិបត្តិការនានាដែលពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម រួមបញ្ចូលថវិកាសម្រាប់គាំទ្រគម្រោង សកម្មភាពនៃ ផ.ស.រ.គ.
- សហការ និងកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម
- រៀបចំ និងបញ្ចូលថវិកាគាំទ្រការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត ផអ៥ទី២ និងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ។

សកម្មភាពជាអាទិភាព ៤.៥. វិភាជថវិកាដើម្បីគាំទ្រ ផ.ស.ថ. ស្តីពីការអនុវត្តការងារ
គណនេយ្យភាពសង្គមដោយរដ្ឋបាលក្រុង ស្រុក

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- ពិនិត្យ និងបែងចែកថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌសម្រាប់ កជទី២ ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម
- ពិនិត្យ និងវិភាជថវិកាពីសមាសភាគសេវាសង្គម និងអនាម័យបរិស្ថាននៃមូលនិធិក្រុង ស្រុក និងថវិកាគុណប្រយោជន៍នៃថវិកាខណ្ឌប្រចាំឆ្នាំ ដើម្បីគាំទ្រសកម្មភាព និងកិច្ចប្រតិបត្តិការនានាដែលបានកំណត់ក្នុង ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម រួមបញ្ចូលថវិកាសម្រាប់គាំទ្រគម្រោង សកម្មភាពនៃ ផ.ស.រ.គ. ផ្អែកតាមគោលការណ៍ និងសេចក្តីណែនាំដែលបានកំណត់
- សហការ និងកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម
- រៀបចំ និងបញ្ចូលថវិកាគាំទ្រការងារគណនេយ្យភាពសង្គមក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត ផអ៥ទី២ និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌ។

សកម្មភាពជាអាទិភាព ៤.៦. ៖ វិភាជថវិកាដើម្បីគាំទ្រ ផ.ស.ថ. ស្តីពីការអនុវត្តការងារ
គណនេយ្យភាពសង្គម ដោយរដ្ឋបាលឃុំ សង្កាត់

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- ពិនិត្យ និងវិភាជថវិកាពីសមាសភាគសេវាសង្គម និងអនាម័យបរិស្ថានៃមូលនិធិឃុំ សង្កាត់ប្រចាំឆ្នាំ ដើម្បីគាំទ្រសកម្មភាព និងប្រតិបត្តិការនានាដែលបានកំណត់ក្នុង ផ.ស.ថ.

ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម និងគម្រោង សកម្មភាពដែលបានកំណត់ក្នុង ផ.ស.រ.គ. ផ្អែកតាមគោលការណ៍ និងសេចក្តីណែនាំដែលបានកំណត់

- សហការ និងកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម
- រៀបចំ និងបញ្ចូលថវិកាគាំទ្រការងារគណនេយ្យភាពសង្គមក្នុងម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់។

សកម្មភាពជាអាទិភាព ៤.៧. ៖ វិភាជថវិកាដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម ដោយមណ្ឌលសុខភាព និងសាលាបឋមសិក្សា

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- ពិនិត្យ និងវិភាជថវិការបស់ខ្លួន ដើម្បីគាំទ្រកិច្ចប្រតិបត្តិការ និងសកម្មភាពនានានៃការងារគណនេយ្យភាពសង្គម និងគម្រោង សកម្មភាពដែលបានកំណត់ ក្នុង ផ.ស.រ.គ.
- សហការ និងកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម
- រៀបចំ និងបញ្ចូលថវិកាដែលបានវិភាជសម្រាប់ការងារគណនេយ្យភាពសង្គមក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

យុទ្ធសាស្ត្រទី៥ ៖ ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គម

យុទ្ធសាស្ត្រនេះផ្តោតលើការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ ដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានាអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ដើម្បីធានាថា រដ្ឋបាលឃុំ សង្កាត់ និងអង្គភាពផ្តល់សេវានានាបានអនុវត្តការងារគណនេយ្យភាពសង្គម ប្រកបដោយការចូលរួម ប្រសិទ្ធភាព គណនេយ្យភាព និងនិរន្តរភាព។

ដើម្បីសម្រេចបានយុទ្ធសាស្ត្រនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានរៀបរាប់ដូចខាងក្រោម ៖

សកម្មភាពជាអាទិភាព ៥.១. ៖ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ដោយ គ.គ.អ.ស.

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- រៀបចំកិច្ចប្រជុំរបស់ គ.គ.អ.ស. ជាប្រចាំ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់
- ចុះតាមដាន និងត្រួតពិនិត្យការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់
- ពង្រឹងទំនាក់ទំនង និងកិច្ចសហការរវាង គ.គ.អ.ស. ជាក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានាក្នុងដោះស្រាយ និងឆ្លើយតបចំពោះបញ្ហា និងតម្រូវការនានាដែលបានលើកឡើងដោយរដ្ឋបាលឃុំ សង្កាត់ពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម

- ពិនិត្យ និងបញ្ចូលបញ្ហានានាពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមនៅឃុំ សង្កាត់ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់ គ.ជ.អ.ប. ដើម្បីពិភាក្សា និងដោះស្រាយ។

សកម្មភាពជាអាទិភាព ៥.២. ៖ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ដោយអង្គភាពត្រួតពិនិត្យ និងវាយតម្លៃនៃលេខាធិការដ្ឋាន គ.ជ.អ.ប.

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងកិច្ចប្រជុំផ្សេងទៀតតាមការចាំបាច់ ជាមួយក្រុមការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម
- សម្របសម្រួល និងសហការជាមួយអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីជាតិនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីដាក់បញ្ចូលរបៀបវារៈនៃការកងារគណនេយ្យភាពសង្គមនៅក្នុងកិច្ចប្រជុំស្តីពីការអនុវត្ត ផ.ស.ថ. នៃ កជទី២
- ចុះត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់
- រៀបចំ និងការផ្សព្វផ្សាយរបាយការណ៍ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់។

សកម្មភាពជាអាទិភាព ៥.៣. ៖ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ដោយក្រុមការងារគណនេយ្យភាពសង្គមថ្នាក់រាជធានី ខេត្ត

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមរបស់រាជធានី ខេត្ត ជាពិសេសការអភិវឌ្ឍសមត្ថភាព និងការគាំទ្រការងារគណនេយ្យភាពសង្គមថ្នាក់ក្រុង ស្រុក ខណ្ឌ
- ចុះតាមដាន និងត្រួតពិនិត្យការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- រៀបចំ និងផ្សព្វផ្សាយរបាយការណ៍ស្តីពីការអនុវត្ត ការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

សកម្មភាពជាអាទិភាព ៥.៤. ៖ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ដោយបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់រាជធានី ខេត្ត

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់បណ្ដាញ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់បណ្ដាញ
- ចុះតាមដាន ត្រួតពិនិត្យ និងគាំទ្របណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ឃុំ សង្កាត់
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តការងារ ដើម្បីដាក់ជូនរដ្ឋបាលរាជធានី ខេត្ត និងភាគីពាក់ព័ន្ធនានា។

សកម្មភាពជាអាទិភាព ៥.៥. ៖ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ដោយក្រុមការងារគណនេយ្យភាពសង្គមក្រុង ស្រុក ខណ្ឌ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាព និងថវិកាស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមរបស់ក្រុង ស្រុក ខណ្ឌ ជាពិសេសការអភិវឌ្ឍសមត្ថភាព និង ផ.ស.រ.គ.
- ចុះតាមដាន ត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់
- រៀបចំ និងផ្សព្វផ្សាយរបាយការណ៍ស្តីពីការអនុវត្ត ការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

សកម្មភាពជាអាទិភាព ៥.៦. ៖ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ដោយបណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់បណ្ដាញ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់បណ្ដាញ
- ចុះតាមដាន ត្រួតពិនិត្យ និងគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តការងារ ដើម្បីដាក់ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងភាគីពាក់ព័ន្ធនានា។

សកម្មភាពជាអាទិភាព ៥.៧. ៖ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ដោយគណៈកម្មាធិការ ផ.ស.រ.គ.

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- រៀបចំកិច្ចប្រជុំប្រចាំខែឱ្យបានទៀងទាត់ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម និង ផ.ស.រ.គ.

- ចុះតាមដាន និងត្រួតពិនិត្យសកម្មភាពនានានៃ ផ.ស.រ.គ. ដែលអនុវត្តដោយអង្គភាពផ្តល់សេវា និងភាគីពាក់ព័ន្ធនានា
- ពង្រឹងការរៀបចំ និងការផ្សព្វផ្សាយរបាយការណ៍ស្តីពីការអនុវត្ត ផ.ស.រ.គ.។

យុទ្ធសាស្ត្រទី៦ ៖ ការលើកកម្ពស់ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងការងារគណនេយ្យភាពសង្គម តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលនៅថ្នាក់ឃុំ សង្កាត់

បច្ចុប្បន្ន ប្រព័ន្ធទិន្នន័យត្រួតពិនិត្យការងារគណនេយ្យភាពសង្គម ត្រូវបានប្រើប្រាស់យ៉ាងសកម្ម និងប្រកបដោយប្រសិទ្ធភាព ដោយអង្គភាពផ្តល់សេវានានានៅថ្នាក់ឃុំ សង្កាត់ក្នុងការរៀបចំ និងផលិតព័ត៌មានស្តីពីលទ្ធផលនៃការបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីរួមចំណែកក្នុងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ ទន្ទឹមនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានបង្កើត និងដាក់ឱ្យដំណើរការនូវកម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គម ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ លទ្ធផលនៃការបំពេញការងាររបស់អង្គភាពផ្តល់សេវា និងការផ្តល់មតិយោបល់របស់ប្រជាពលរដ្ឋ និងសាធារណជននានាលើការបំពេញការងារ និងការផ្តល់សេវា។

យុទ្ធសាស្ត្រនេះផ្តោតលើការបង្កើត ដាក់ឱ្យដំណើរ និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យនានា ដើម្បីលើកកម្ពស់ការប្រើប្រាស់ និងការគ្រប់គ្រងដោយអង្គភាពផ្តល់សេវានានានៅថ្នាក់ឃុំ សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

ដើម្បីសម្រេចបានយុទ្ធសាស្ត្រនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានរៀបរាប់ដូចខាងក្រោម ៖

សកម្មភាពជាអាទិភាព ៦.១. ៖ គ្រប់គ្រង និងថែរក្សាជាប្រចាំនូវប្រព័ន្ធទិន្នន័យ និងឧបករណ៍ពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម ដោយអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប.

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- គ្រប់គ្រង និងថែរក្សាជាប្រចាំនូវប្រព័ន្ធទិន្នន័យនានាពាក់ព័ន្ធនឹងគណនេយ្យភាពសង្គម ដូចជាប្រព័ន្ធទិន្នន័យត្រួតពិនិត្យនិងវាយតម្លៃការងារគណនេយ្យភាពសង្គម កម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គម ប្រព័ន្ធឌីជីថលសម្រាប់វាយតម្លៃលទ្ធផលបំពេញការងាររបស់អង្គភាពផ្តល់សេវា
- ពិនិត្យ កែសម្រួល និងរៀបចំកញ្ចប់ព័ត៌សម្រាប់ប្រជាពលរដ្ឋ ដើម្បីផ្ញើជូនអង្គភាពផ្តល់សេវាឱ្យបានទាន់ពេលវេលា ដើម្បីបោះពុម្ព និងផ្សព្វផ្សាយ
- អភិវឌ្ឍសមត្ថភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីបន្តអភិវឌ្ឍសមត្ថភាព និងគាំទ្ររដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងការប្រើប្រាស់ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងឧបករណ៍នានាពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម

- ត្រួតពិនិត្យ និងផ្តល់ការគាំទ្រជាប្រចាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រើប្រាស់ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យ។

សកម្មភាពជាអាទិភាព ៦.២. ៖ អង្គភាពផ្តល់សេវានានានៅថ្នាក់ឃុំ សង្កាត់ប្រើប្រាស់ប្រព័ន្ធទិន្នន័យត្រួតពិនិត្យ និងវាយតម្លៃការងារគណនេយ្យភាពសង្គម សម្រាប់ការ រៀបចំ ផ.ស.រ.គ. ប្រកបដោយប្រសិទ្ធភាព

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- កំណត់ និងអភិវឌ្ឍសមត្ថភាពមន្ត្រីបង្គោលទទួលបន្ទុកប្រព័ន្ធទិន្នន័យត្រួតពិនិត្យ និងវាយតម្លៃការងារគណនេយ្យភាពសង្គម
- អង្គភាពផ្តល់សេវាបញ្ចូលព័ត៌មាន និងផលិតទិន្នន័យស្តីពីលទ្ធផលនៃការបំពេញការងារ និងការផ្តល់សេវាក្នុងប្រព័ន្ធទិន្នន័យត្រួតពិនិត្យ និងវាយតម្លៃការងារគណនេយ្យភាពសង្គម សម្រាប់រៀបចំ ផ.ស.រ.គ. ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ស្របតាមសេចក្តីណែនាំដែលបានកំណត់។
- គ្រប់គ្រង និងថែរក្សាប្រព័ន្ធទិន្នន័យត្រួតពិនិត្យនិងវាយតម្លៃការងារគណនេយ្យភាពសង្គមជាប្រចាំ។

សកម្មភាពជាអាទិភាព ៦.៣. ៖ អង្គភាពផ្តល់សេវានានានៅថ្នាក់ឃុំ សង្កាត់លើកកម្ពស់ការផ្សព្វផ្សាយអំពីការប្រើប្រាស់កម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គម ជូនប្រជាពលរដ្ឋ និងសាធារណជន

សកម្មភាពនេះផ្តោតលើការលើកកម្ពស់ការការយល់ដឹងរបស់ប្រជាពលរដ្ឋ និងសាធារណជននានាអំពីស្តង់ដានៃសេវា និងសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវសេវានានាដែលផ្តល់ដោយអង្គភាពផ្តល់សេវានៅថ្នាក់ក្រោមជាតិ តាមរយៈការប្រើប្រាស់កម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គម សំដៅលើកកម្ពស់ការចូលរួមពួកគាត់ក្នុងការបំពេញការងារ និងការផ្តល់សេវារបស់អង្គភាពផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព។

ដើម្បីសម្រេចបាននូវសកម្មភាពនេះ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- កំណត់ និងបណ្តុះបណ្តាលមន្ត្រីបង្គោលទទួលបន្ទុកកម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គម
- លើកកម្ពស់ការផ្សព្វផ្សាយអំពីកម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គមជូនប្រជាពលរដ្ឋ និងសាធារណជននានានៅតាមអង្គភាពផ្តល់សេវា និងក្នុងព្រិត្តិ◌ុការណ៍ផ្សេងៗ
- ត្រួតពិនិត្យ និងគាំទ្រប្រជាពលរដ្ឋ និងសាធារណជនក្នុងការប្រើប្រាស់កម្មវិធីទូរសព្ទដៃគណនេយ្យភាពសង្គម។

សកម្មភាពជាអាទិភាព ៦.៤. ៖ រៀបចំ និងដាក់ឱ្យដំណើរការនូវប្រព័ន្ធឌីជីថលសម្រាប់ការវាយតម្លៃលទ្ធផលបំពេញការងាររបស់អង្គភាពផ្តល់សេវា

ប្រព័ន្ធឌីជីថលសម្រាប់វាយតម្លៃលទ្ធផលបំពេញការងាររបស់អង្គភាពផ្តល់សេវា ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងឆ្នាំ២០២៦ ក្នុងគោលបំណងធ្វើទំនើបកម្មវិធីសាស្ត្រសម្រាប់ការវាយតម្លៃ និងការដាក់ពិន្ទុលើលទ្ធផលនៃការផ្តល់សេវា និងការរៀបចំផែនការសកម្មភាពស្តីពីការងារគណនេយ្យភាពសង្គមតាមប្រព័ន្ធឌីជីថល ប្រកបដោយប្រសិទ្ធភាព និងស្របតាមពេលវេលាកំណត់។

ដើម្បីសម្រេចបាននូវសកម្មភាពនេះ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំ និងដាក់ឱ្យដំណើរការប្រព័ន្ធនូវឌីជីថលសម្រាប់វាយតម្លៃលទ្ធផលបំពេញការងាររបស់អង្គភាពផ្តល់សេវា និងការរៀបចំផែនការសកម្មភាពស្តីពីការងារគណនេយ្យភាពសង្គម
- បណ្តុះបណ្តាលរដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលអង្គភាពផ្តល់សេវានៅថ្នាក់ឃុំ សង្កាត់ អំពីការប្រើប្រាស់ប្រព័ន្ធនេះ
- លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធឌីជីថល សម្រាប់ការវាយតម្លៃលទ្ធផលបំពេញការងារក្នុងដំណើរការកសាងផែនការសកម្មភាពស្តីពីគណនេយ្យភាពសង្គម
- ពង្រឹងការត្រួតពិនិត្យ និងផ្តល់ការគាំទ្រជាប្រចាំដល់អង្គភាពផ្តល់សេវាក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការវាយតម្លៃលទ្ធផលបំពេញការងារ។

សកម្មភាពជាអាទិភាព ៦.៥. ៖ អង្គភាពផ្តល់សេវាបោះពុម្ព និងផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ជូនប្រជាពលរដ្ឋជាប្រចាំ

ដើម្បីសម្រេចបាននូវសកម្មភាពនេះ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- រៀបចំ និងបោះពុម្ពកញ្ចប់ព័ត៌សម្រាប់ប្រជាពលរដ្ឋជាប្រចាំ និងទាន់ពេលវេលា
- អង្គភាពផ្តល់សេវា និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ផ្សព្វផ្សាយកញ្ចប់ព័ត៌សម្រាប់ប្រជាពលរដ្ឋជូនប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីស្តង់ដាសេវា សិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានសេវា និងការវាយតម្លៃអំពីលទ្ធផលនៃការបំពេញការងាររបស់អង្គភាពផ្តល់សេវា
- ត្រួតពិនិត្យការបិទផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ នៅតាមអង្គភាពផ្តល់សេវា និងទីសាធារណៈនានា។

យុទ្ធសាស្ត្រទី៧ ៖ ការជ្រើសរើស និងគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងបង្កើតបណ្តាញ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

ការអនុវត្តការងារគណនេយ្យភាពសង្គមបែងចែកជា០២ ផ្នែក គឺផ្នែកផ្គត់ផ្គង់ដែលទទួលខុសត្រូវដោយអង្គភាពផ្តល់សេវា និងផ្នែកតម្រូវការដែលទទួលខុសត្រូវដោយអង្គការសង្គមស៊ីវិល តាមរយៈអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។ បច្ចុប្បន្ន អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ឃុំ សង្កាត់ (CAF) មានចំនួនជាង ៤.០០០ នាក់ (ជាមធ្យមចំនួន៣-៥នាក់ក្នុង១ឃុំ សង្កាត់) ក្នុងនោះមាន

ស្ត្រីចំនួន៦៥% បាន និងកំពុងបំពេញតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងការសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ ប្រកបដោយប្រសិទ្ធភាព និងឯករាជ្យភាព ដោយសហការជិតស្និទ្ធជាមួយរដ្ឋបាលឃុំ សង្កាត់ អង្គភាពផ្តល់សេវា និងភាគីពាក់ព័ន្ធផ្សេងទៀត។ ទន្ទឹមនេះ បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ក៏ត្រូវបានបង្កើតក្នុងរាជធានី ខេត្តចំនួន២១ និងក្រុង ស្រុក ខណ្ឌចំនួន១២៨ ដើម្បីដឹកនាំ អភិវឌ្ឍសមត្ថភាព និងគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។

យុទ្ធសាស្ត្រនេះផ្តោតលើការជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅគ្រប់ឃុំ សង្កាត់ និងបង្កើតបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដើម្បីសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការដោយសហការជិតស្និទ្ធជាមួយរដ្ឋបាលឃុំ សង្កាត់ និងអង្គភាពផ្តល់សេវាផ្សេងទៀត។

ដើម្បីសម្រេចបានយុទ្ធសាស្ត្រនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានរៀបរាប់ដូចខាងក្រោម ៖

សកម្មភាពជាអាទិភាព ៧.១. ៖ ជ្រើសរើស និងគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ នៅគ្រប់គ្រប់ឃុំ សង្កាត់ទូទាំងប្រទេស

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- ឃុំ សង្កាត់ទាំងអស់ត្រូវរក្សា និងគាំទ្រ CAF ដែលមានស្រាប់នៅតាមឃុំ សង្កាត់នីមួយៗ ស្របតាមសៀវភៅណែនាំប្រតិបត្តិស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម នៅថ្នាក់ឃុំ សង្កាត់ ដើម្បីបន្តសម្របសម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការដោយប្រើប្រាស់ថវិកាសេវាសង្គម និងអនាម័យស្ថាននៃមូលនិធិឃុំ សង្កាត់ និងថវិកាពីប្រភពផ្សេងទៀត។
- រៀបចំ និងដាក់ចេញសេចក្តីណែនាំស្តីពីការជ្រើសរើស ការគ្រប់គ្រង និងគាំការទ្រ CAF នៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស ដោយ គ.ជ.អ.ប.
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បណ្តាញ CAF និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ត្រូវរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាព ការត្រួតពិនិត្យ និងផ្តល់ការគាំទ្រជាប្រចាំដល់ការបំពេញការងាររបស់ CAF។

សកម្មភាពជាអាទិភាព ៧.២. ៖ បង្កើត និងទទួលស្គាល់បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ

កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសកម្មភាពនេះរួមមាន ៖

- គ.ជ.អ.ប. រៀបចំ និងដាក់ចេញនូវសេចក្តីណែនាំស្តីពីការបង្កើត និងទទួលស្គាល់បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក

ខណ្ឌទូទាំងប្រទេស រួមបញ្ចូលថវិកាសម្រាប់គាំទ្របណ្ដាញទាំងនេះ

- រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបង្កើត និងទទួលស្គាល់បណ្ដាញ ស្រប តាមការណែនាំរបស់ថ្នាក់ជាតិ
- អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ត្រូវសហការ និងចូលរួមបង្កើត អភិវឌ្ឍសមត្ថភាព និង គាំទ្របណ្ដាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដើម្បីជានាការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។

យុទ្ធសាស្ត្រទី៨ ៖ ការបង្កើតភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាក្នុង ការអនុវត្តការងារគណនេយ្យភាពសង្គម

ការងារគណនេយ្យភាពសង្គម ត្រូវបានអនុវត្ត ស្ថិតក្រោមការងារដឹកនាំ និងសម្របសម្រួលរបស់ គ.គ.អ.ស. និងដោយមានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសេនាធិការ។ កន្លងមក គ.គ.អ.ស. បានសម្របសម្រួល និងសហការយ៉ាងជិតស្និទ្ធជាមួយជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីចូលរួម និងគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រស្ដីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានដូចជា WB, SDC, DFAT, ISD/GIZ, World Vision, CARE, FHI 360, OXFAM, Save the Children, RACHA, STAR Kampuchea ហើយអង្គការទាំងនេះក៏បានចូលរួមបដិភាគថវិកាសម្រាប់អនុវត្តការងារនេះ។

យុទ្ធសាស្ត្រនេះផ្ដោតលើការបន្តលើកកម្ពស់ការសម្របសម្រួល និងកិច្ចសហការរបស់ គ.គ.អ.ស. និងក្រុមការងារគណនេយ្យភាពសង្គមនៃលេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល រួមបញ្ចូលអង្គការសហគមន៍មូលដ្ឋាននានា ដើម្បីចូលរួម និងផ្ដល់មូលនិធិសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម។

ដើម្បីសម្រេចបានយុទ្ធសាស្ត្រនេះ សកម្មភាពជាអាទិភាពដែលត្រូវអនុវត្តមានរៀបរាប់ដូចខាងក្រោម ៖

សកម្មភាពជាអាទិភាព ៨.១. ៖ សម្របសម្រួល និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិលនានា ដោយ គ.គ.អ.ស. អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. និង រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តការងារគណនេយ្យភាព សង្គម

ដើម្បីសម្រេចបាននូវសកម្មភាពនេះ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- លើកកម្ពស់ការរៀបចំ និងផ្សព្វផ្សាយអំពីសមិទ្ធផល និងផលប៉ះពាល់ជាវិជ្ជមាននានានៃ ការអនុវត្តការងារគណនេយ្យភាពសង្គមដល់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា តាមមធ្យោបាយ និងឧបករណ៍ផ្សេងៗ
- រៀបចំព្រឹត្តិការណ៍ប្រចាំឆ្នាំស្ដីពីការអនុវត្តការងារគណនេយ្យភាពសង្គម ដោយមានការ ចូលរួមពីភាគីពាកព័ន្ធនានា ដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្ដល់

សេវា អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធនានា

- សម្របសម្រួល និងសហការជាប្រចាំជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម តាមរយៈយន្តការនានា ដូចជាកិច្ចប្រជុំរបស់ គ.គ.អ.ស. លេខាធិការដ្ឋាន គ.ជ.អ.ប. អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងយន្តការពាក់ព័ន្ធផ្សេងទៀត
- សហការ និងចូលរួមក្នុងសកម្មភាព និងព្រឹត្តិការណ៍នានាដែលរៀបចំដោយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម
- ទំនាក់ទំនង និងរៀបចំសំណើគម្រោង និងកម្មវិធីនានាស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ដើម្បីកៀរគរថវិកាពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។

### សកម្មភាពជាអាទិភាព ៨.២. ៖ កៀរគរធនធានពីប្រភពនានាសម្រាប់គាំទ្រគម្រោង និងសកម្មភាពនានានៃ ផ.ស.រ.គ

បច្ចុប្បន្ន ថវិកា និងមុខសញ្ញាចំណាយសម្រាប់ការងារគណនេយ្យភាពសង្គម ត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋាភិបាល ដូចជាអនុក្រឹត្យលេខ១៥៣ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ និងសារាចរអន្តរក្រសួងលេខ០០៧ស្តីពីការគ្រប់គ្រង ការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យ-បរិស្ថាននៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។ ក្នុងន័យនេះ រដ្ឋបាលឃុំ សង្កាត់ដែលអាចប្រើប្រាស់ជាផ្លូវការនូវថវិការបស់ខ្លួន ដើម្បីគាំទ្រប្រតិបត្តិការ និងសកម្មភាពនានានៃ ផ.ស.រ.គ.។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅ តម្រូវកាថវិកាសម្រាប់គាំទ្រសកម្មភាពនានានៃ ផ.ស.រ.គ. មានទំហំលើសពីសមត្ថភាពរបស់ឃុំ សង្កាត់ដែលទាមទារនូវការគាំទ្របន្ថែមពីប្រភពផ្សេងទៀតនៃស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។

សកម្មភាពនេះផ្តោតលើការពង្រឹងការយកចិត្តទុកដាក់ និងផ្តល់អាទិភាពរបស់រដ្ឋបាលឃុំ សង្កាត់ក្នុងការសម្របសម្រួល និងកិច្ចសហការជាមួយស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា ដើម្បីចូលរួម និងផ្តល់មូលនិធិសម្រាប់គាំទ្រប្រតិបត្តិការនៃការងារគណនេយ្យភាពសង្គម និងសកម្មភាពនានានៃ ផ.ស.រ.គ.។

ដើម្បីសម្រេចបាននូវសកម្មភាពនេះ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- ក្រុង ស្រុក ខណ្ឌ ត្រូវសម្របសម្រួល និងការរៀបចំសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ប្រកបដោយប្រសិទ្ធភាព ដោយធានាឱ្យមានការចូលរួមពីស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា
- ឃុំ សង្កាត់ត្រូវធានាការរៀបចំ និងបញ្ចូល ផ.ស.រ.គ. ក្នុងបញ្ជីគម្រោង សកម្មភាពរបស់ឃុំ សង្កាត់ដែលត្រូវបង្ហាញក្នុងសិក្ខាសាលាសមាហរណកម្ម

- ឃុំ សង្កាត់លើកកម្ពស់ការផ្សព្វផ្សាយ ផ.ស.រ.គ. តាមរយៈមធ្យោបាយ និងឧបករណ៍ផ្សេងៗ ដើម្បីកៀរគរធនធានសម្រាប់អនុវត្តផែនការនេះ។

សកម្មភាពជាអាទិភាព ៨.៣. ៖ បង្កើនកិច្ចសហការ និងការចូលរួមរបស់អង្គការសហគមន៍មូលដ្ឋាន ដោយរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ

សកម្មភាពនេះផ្ដោតលើការបង្កើតភាពជាដៃគូ កិច្ចសហការ និងការចូលរួមរបស់អង្គការសហគមន៍មូលដ្ឋាននានាក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការនៅថ្នាក់ឃុំ សង្កាត់ឱ្យកាន់តែមានប្រសិទ្ធភាព អព្យាក្រឹតភាព និងនិរន្តភាព។

ដើម្បីសម្រេចបាននូវសកម្មភាពនេះ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តរួមមាន ៖

- រដ្ឋបាលឃុំ សង្កាត់ប្រមូល និងរៀបចំព័ត៌មានអំពីអង្គការសហគមន៍មូលដ្ឋាននានាដែលមាននៅក្នុងមូលដ្ឋានរបស់ខ្លួន
- បង្កើតទំនាក់ទំនង និងកិច្ចសហការជាប្រចាំជាមួយអង្គការសហគមន៍មូលដ្ឋាននានាដែលមានវត្តមានក្នុងឃុំ សង្កាត់ ដើម្បីចូលរួមផ្សព្វផ្សាយ និងអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់
- យកចិត្តទុកដាក់ និងកៀរគរការចូលរួមរបស់សមាជិកនៃអង្គការសហគមន៍មូលដ្ឋាននានាក្នុងការបំពេញតួនាទីជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
- ផ្សព្វផ្សាយ និងអប់រំអំពីការងារគណនេយ្យភាពសង្គម និងការងារពាក់ព័ន្ធនានាដល់អង្គការសហគមន៍មូលដ្ឋាន។

## ៧. ការគ្រប់គ្រង និងការអនុវត្ត

ការអនុវត្តយុទ្ធសាស្ត្រស្ដីពីនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ស្ថិតក្រោមការដឹកនាំ និងការសម្របសម្រួលរបស់ គ.គ.អ.ស. ដោយមានអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសេនាធិការ។

នៅតាមក្រសួង ស្ថាប័ន ការអនុវត្តយុទ្ធសាស្ត្រស្ដីពីនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ស្ថិតក្រោមការដឹកនាំ និងការសម្របសម្រួលរបស់ គ.ដ.វ.រ. និងដោយមានការជួយគាំទ្រពីមន្ត្រីបង្គោលគណនេយ្យភាពសង្គម។

នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ការអនុវត្តយុទ្ធសាស្ត្រស្ដីពីនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ស្ថិតក្រោមការដឹកនាំ និងការសម្របសម្រួលរបស់ក្រុមការងារគណនេយ្យភាពសង្គម ដោយមានការជួយគាំទ្រពីមន្ត្រីបង្គោលគណនេយ្យភាពសង្គម។

នៅថ្នាក់ឃុំ សង្កាត់ ការអនុវត្តយុទ្ធសាស្ត្រស្ដីពីនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ស្ថិតក្រោមការដឹកនាំ និងសម្របសម្រួលរបស់គណៈកម្មាធិការ ផ.ស.រ.គ. ដោយមានការជួយគាំទ្រ

ពីមន្ត្រីបង្គោលគណនេយ្យភាពសង្គម និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។

ការអនុវត្តយុទ្ធសាស្ត្រនេះ ត្រូវធ្វើឡើងតាមរយៈផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមដែលត្រូវរៀបចំ និងអនុវត្តដោយស្ថាប័នអនុវត្តនីមួយៗ រួមមានក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា។ ក្នុងន័យនេះ ជារៀងរាល់ឆ្នាំ ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា ត្រូវកំណត់ និងបញ្ចូលសកម្មភាពជាអាទិភាពនៃការងារគណនេយ្យភាពទៅក្នុង ផ.ស.ថ. ស្តីពីការអនុវត្ត ផអ៥ទី២ របស់ខ្លួន ព្រមទាំងថវិកាថវិកាសម្រាប់គាំទ្រសកម្មភាពទាំងនេះឱ្យបានសមស្រប។

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវជួយ គ.គ.អ.ស. ក្នុងការគ្រប់គ្រង ការសម្របសម្រួល និងការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្តយុទ្ធសាស្ត្រ រួមបញ្ចូលការរៀបចំ ផ.ស.ថ. និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម។ ទន្ទឹមនេះ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ក៏មានភារកិច្ចក្នុងការសម្របសម្រួល និងផ្តល់ការគាំទ្រដល់ស្ថាប័នអនុវត្ត និងភាគីពាក់ព័ន្ធនានាក្នុងការរៀបចំ និងការអនុវត្ត ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ដោយសហការជិតស្និទ្ធជាមួយអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប.។

គ.គ.អ.ស. និងអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវពង្រឹងការសម្របសម្រួល កិច្ចសហការ និងការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានាសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម។

## ៨. ការត្រួតពិនិត្យ និងការវាយតម្លៃ

ក្នុងនាម គ.គ.អ.ស. អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំលើការអនុវត្តយុទ្ធសាស្ត្រស្តីពីនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា (យុទ្ធសាស្ត្រទី១) ទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត ផ.ស.ថ. ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមរបស់ខ្លួន ដោយមានការជួយគាំទ្រពីអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. (យុទ្ធសាស្ត្រទី៥)។

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការសម្របសម្រួល និងអនុវត្តការ ត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រនិរន្តរភាព រួមមាន ៖

- ការវាយតម្លៃប្រចាំឆ្នាំ
- ការវាយតម្លៃអំពីភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រ

- ការរៀបចំរបាយការណ៍ ៖
    - o របាយការណ៍ប្រចាំខែ
    - o របាយការប្រចាំឆមាស
    - o របាយការណ៍ប្រចាំឆ្នាំ

**៩. ផែនការថវិកា**

៩.១. ផែនការថវិកាក្នុងមួយឆ្នាំ

ផ្អែកតាមបទពិសោធន៍នៃការវិភាជថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតំបន់គោលដៅ ដែលអនុវត្តការងារគណនេយ្យភាពសង្គមពីឆ្នាំ២០២៥-២០២៦ ជាមធ្យមក្នុងមួយឆ្នាំ រដ្ឋបាលរាជធានី ខេត្តបានវិភាជ ថវិកាចំនួន ៨០០ លានរៀល ស្មោះនឹង ២០.០០០ ដុល្លារ រដ្ឋបាលក្រុង ស្រុក ខណ្ឌបានវិភាជថវិកាចំនួន ៨ លានរៀល ស្មើនឹង ២.០០០ ដុល្លារ និងរដ្ឋបាលឃុំ សង្កាត់បានវិភាជថវិកាចំនួន ៤ លានរៀល ស្មើនឹង ១.០០០ ដុល្លារ ដើម្បីគាំទ្រការងារគណេនេយ្យភាពសង្គម រួមបញ្ចូលចំណាយប្រតិបត្តិការ និងការគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។

ផ្អែកលើមូលដ្ឋានខាងលើនេះ ថវិកាប៉ាន់ស្មានសរុបសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គមក្នុងមួយឆ្នាំនៅថ្នាក់ក្រោមជាតិមានចំនួនប្រមាណ ១០.២៨៨ លានរៀល ស្មើនឹង ២,៥ លានដុល្លារ ក្នុងនោះថវិកាថ្នាក់ រាជធានី ខេត្តមានចំនួន ២.០០០ លានរៀល ស្មើនឹង ៥០០.០០០ ដុល្លារ ថ្នាក់ក្រុង ស្រុក ខណ្ឌមានចំនួន ១.៦៨០ លានរៀល ស្មើនឹង ៤២០.០០០ ដុល្លារ និងថ្នាក់ឃុំ សង្កាត់មានចំនួន ៦.៦០៨ លានរៀល ស្មើនឹង ១,៦ លានដុល្លារ។ ថវិកាប៉ាន់ស្មាននេះ មិនគិតបញ្ចូលថវិកាសម្រាប់អនុវត្តសកម្មភាព ផ.ស.រ.គ. ទេ។

ក្រៅពីថវិកាដែលបានរៀរាប់ខាងលើ នៅមានថវិកាមួយចំនួនទៀតរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាដែលបានវិភាជថវិកា ដើម្បីគាំទ្រការងារគណនេយ្យភាពសង្គម។

៩.២. ប្រភពថវិកា

ប្រភពមូលនិធិសំខាន់ៗសម្រាប់គាំទ្រការអនុវត្តយុទ្ធសាស្ត្រនិន្តរភាពរួមមាន ៖

- ថវិការបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ
    - o ថវិកាសម្រាប់អនុវត្តយុទ្ធសាស្ត្រ គឺជាផ្នែកមួយនៃថវិការបស់ក្រសួង ស្ថាប័នសម្រាប់អនុវត្ត ផអ៥ទី២
- ថវិការបស់រាជធានី ខេត្ត និងខណ្ឌ
    - o ថវិកាសម្រាប់អនុវត្តយុទ្ធសាស្ត្រ រួមមាន ៖
        - ▪ ថវិកាសម្រាប់អនុវត្ត ផអ៥ទី២
        - ▪ ថវិកាសម្រាប់អនុវត្តសេវាសង្គម ដែលត្រូវវិភាជជារៀងរាល់ឆ្នាំយ៉ាងតិចចំនួន ១០% នៃថវិកាអភិវឌ្ឍ ឬថវិកាគុណប្រយោាជន៍របស់រដ្ឋបាលរាជធានី ខេត្ត និងខណ្ឌ ស្របតាមការណែនាំរបស់ក្រសួងមហាផ្ទៃ។
- ថវិការបស់មន្ទីរ អង្គភាពជំនាញថ្នាក់រាជធានី ខេត្ត

- ថវិកាសម្រាប់អនុវត្តយុទ្ធសាស្ត្រ បានមកពី ៖
  - ថវិកាសម្រាប់ប្រតិបត្តិការ និងសកម្មភាពនានាសម្រាប់ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រអង្គភាពផ្តល់សេវានៅថ្នាក់ឃុំ សង្កាត់
  - ថវិកាគាំទ្រសកម្មភាពនានានៃ ផ.ស.រ.គ.

- មូលនិធិក្រុង ស្រុក ៖
  - ថវិកាសម្រាប់អនុវត្តយុទ្ធសាស្ត្រ គឺជាផ្នែកមួយនៃ ៖
    - ថវិកាសម្រាប់អនុវត្ត ផអ៥ទី២
    - ថវិកាសម្រាប់សេវាសង្គម និងអនាម័យបរិស្ថាន
- មូលនិធិឃុំ សង្កាត់ ៖
  - ថវិកាសម្រាប់អនុវត្តយុទ្ធសាស្ត្រ បានមកពី ៖
    - ថវិកាសម្រាប់អនុវត្ត ផអ៥ទី២
    - ថវិកាសម្រាប់សេវាសង្គម និងអនាម័យបរិស្ថាន
- មូលនិធិដៃគូអភិវឌ្ឍន៍
  - WB
  - GIZ/ISD
  - DFAT
  - SDC
- ថវិការបស់អង្គការសង្គមស៊ីវិលនានា
  - WVC
  - CARE, FHI 360, OXFAM, Save the Children, RACHA, STAR Kampuchea...

**១០. សេចក្តីសន្និដ្ឋាន**

យុទ្ធសាស្ត្រស្តីពីនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់មានសារសំខាន់បំផុតក្នុងការធានាថា ការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់ ត្រូវបានអនុវត្តដោយអង្គភាពផ្តល់សេវានានានៅថ្នាក់ឃុំ សង្កាត់ ដូចជារដ្ឋបាលឃុំ សង្កាត់ មណ្ឌលសុខភាព/ ប៉ុស្តិ៍សុខភាព និង សាលាបឋមសិក្សាប្រកបដោយប្រសិទ្ធភាព តាមរយៈដំណើរការដែលមានការចូលរួមពីប្រជាពលរដ្ឋ និងក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិនានា ដែលទទួលខុសត្រូវក្នុងការសម្រុសបម្រួល និងអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ។ អាស្រ័យហេតុនេះ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានតួនាទី និងភារកិច្ចដឹកនាំ សម្របសម្រួល ការអនុវត្ត និងចូលរួមក្នុងដំណើរការ គណនេយ្យភាពសង្គម ត្រូវពង្រឹងការយកចិត្តទុកដាក់ ផ្តល់អាទិភាព និងផ្តល់ការគាំទ្រ រួមបញ្ចូលការវិភាជ ថវិកាសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម ស្របតាមតួនាទី និងភារកិច្ចរបស់ខ្លួន។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពង្រឹងការរៀបចំលិខិតបទដ្ឋាន ការអភិវឌ្ឍសមត្ថភាព និងគាំទ្រជាប្រចាំ ដល់រដ្ឋបាល

ថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តថវិកាសម្រាប់ការងារគណនេយ្យភាពសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

គ.ជ.អ.ប. មានជំនឿជឿជាក់ថា យុទ្ធសាស្ត្រស្តីពីនិរន្តរភាពការងារគណនេយ្យភាពសង្គមនៅថ្នាក់ឃុំ សង្កាត់នឹងនាំមកនូវសមិទ្ធផលជាច្រើនបន្ថែមទៀតសម្រាប់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សំដៅរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរបស់ កជទី២ គឺ "**ប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពីសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គុណភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម**"។